# មជ្ឈមណ្ឌលឯកសារកម្ពុជា

PTI0084

## សម្ភាសន៍ជាមួយឈ្មោះ ឯក សុផល ភេទប្រុស អាយុ៦៥ឆ្នាំ

មុខងារនៅសម័យខ្មែរក្រហមៈ គណៈតំបន់៣៧ (ស្រែអំបិល)

មុខងារបច្ចុប្បន្នៈ ក្រុមប្រឹក្សាស្រុកវាលវែង

សព្វថ្ងៃរស់នៅភូមិតាកែវ ឃុំពាម ស្រុកកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង

ភូមិចំការជ្រៃខាងជើង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ឡុង ដានី

០២:១០:១៤

៥៩ទំព័រ

ដានី :	ចឹងអ៊ុំជំរាបប្អូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ុំ ឈ្មោះពេញ ឈ្មោះអីដែរ?

សុផល :	ឯក សុផល ។

ដានី :	ឯក សុផល?

សុផល :	បាទ!

ដានី :	អ៊ុំឈ្មោះនឹង មានឈ្មោះបដិវត្ត?

សុផល :	អត់ទេចឹងម៉ង គេប្រែរួចហើយ ដល់ប្រែអី ខ្ញុំអត់ប្រែ ។

ដានី :	ចុះអ៊ុំអាយុប៉ុន្មានហើយសព្វថ្ងៃ?

សុផល :	ខ្ញុំ៦០ជាងហើយ ។

ដានី :	៦០ប៉ុន្មាន?

សុផល :	៦៥ ។

ដានី :	៦៥?

សុផល :	៦៤ ៦៥ឆ្នាំថ្មីនេះ ។

ដានី :	សព្វថ្ងៃនេះ អ៊ុំរស់នៅក្នុងភូមិឃុំអីដែរ?

សុផល :	ភូមិចំការជ្រៃខាងជើង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។

ដានី :	ភូមិចំការជ្រៃខាងត្បូង?

សុផល :	ខាងត្បូង ឡើងមកខាងជើង ស្គាល់ហើយ ។

ដានី :	ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ប្រពន្ធអ៊ុំគាត់ឈ្មោះអីដែរ?

សុផល ៖ ក្មួយនេះស្គាល់ហើយ បើថា ។

ដានី ៖ គាត់ឈ្មោះអីគេ?

សុផល ៖ សុខ រ៉េន ។

ដានី ៖ សុខ រ៉េន? សព្វថ្ងៃ គាត់អាយុប៉ុន្មានហើយ?

សុផល ៖ ៥០ជាងហើយ មិនដឹង៥០ប៉ុន្មានទេ ។

ដានី ៖ ៥០ជាង?

សុផល ៖ បាទ! ៥៥ ៥៦ ។

ដានី ៖ ៥៥ ៥៦? អ៊ំមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

សុផល ៖ ៥ ។

ដានី ៖ ៥នាក់ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

សុផល ៖ ស្រី៣នាក់ ប្រុស២ ។

ដានី ៖ អ៊ំសព្វថ្ងៃធ្វើអីគេ តួនាទីអ៊ំសព្វថ្ងៃ?

សុផល ៖ ខ្ញុំធ្វើក្រុមប្រឹក្សាស្រុក ។

ដានី ៖ ក្រុមប្រឹក្សាស្រុកៗវាលវែងយើងហ្នឹង? ស្រុកវាលវែង?

សុផល ៖ វាលវែង ។

ដានី ៖ អ៊ំចាប់ផ្ដើមធ្វើជាក្រុមប្រឹក្សាស្រុកនឹងតាំងពីអាណត្តិណាមក?

សុផល ៖ អាណត្តិទី១ ។

ដានី ៖ អាណត្តិទី១ ពីឆ្នាំណាមក?

សុផល ៖ អាណត្តិទី១ បើគិតទៅ២ឆ្នាំមកហើយ យើងប្រជុំសាមញ្ញ អាណត្តិទី២២ហើយ ។ ចឹងយើងពីឆ្នាំៗនឹងមិនឆ្នាំ២០១១ ២០១០ ២០០៩ ។

ដានី ៖ ចឹងចាប់ធ្វើ២០០៩ទេ?

សុផល ៖ ទើបរៀបចំៗ និយាយពីប្រវត្តិទូទាំងប្រទេសវារៀបចំដំណើរការជាមួយគ្នានឹង ។ យើងដឹងពីគោលការណ៍របស់រដ្ឋាភិបាលហើយ ។

ដានី ៖ ចុះកាលពីមុន អ៊ំមានតួនាទីជាក្រុមប្រឹក្សាស្រុកអ៊ំធ្វើអី?

សុផល ៖ អានេះខ្ញុំប្រធានស្នាក់ការណ៍អភិរក្សវាលវែងនឹង ។

ដានី ៖ ប្រធានស្នាក់ការណ៍អភិរក្សខាងបរិស្ថានវាលវែងនឹង?

សុផល ៖ បាទ!

ដានី ៖ ចាប់ពីឆ្នាំណាមកដែរ?

សុផល ៖ ចាប់ពីឆ្នាំ២០០០ តែដូនកាលខ្ញុំធ្វើៗតាំងពីឆ្នាំ២០០០ តាំងពី២០០២ ២០០៣ ។

ដានី ៖ បាទ! រហូតមកដល់ឆ្នាំ២០០៩?

សុផល ៖ បាទ! បានចប់ខ្ញុំបានខ្ញុំធ្វើការងារខ្ញុំ ។

ដានី ៖ ចុះអ៊ំស្រុកកំណើរអ៊ំនៅណាទៅ?

សុផល ៖ កំពង់ឆ្នាំង ។

ដានី ៖ ភូមិអីគេដែរ?

សុផល ៖ ភូមិតាកែវ ឃុំពាម ។

ដានី ៖ ភូមិតាកែវ ឃុំពាម? ស្រុកអីនឹង?

សុផល ៖ ស្រុកកំពង់ត្រឡាចលើ ។

ដានី ៖ ស្រុកកំពង់ត្រឡាចលើ?

សុផល ៖ តែឥឡូវគេរៀបចំស្រុកម៉េចទេគេទេ ស្រុកសាមគ្គីមានជ័យម៉េចទេ កាលនឹងដាក់តាមជំនាន់ចាស់ ដល់ខ្ញុំបែកយូរមិនដឹងថាគេរៀបចំម៉េចទេៗអត់ដឹងយល់ម៉េចៗទេ ។

ដានី ៖ បាទ! ស្រុកឥឡូវគេដាក់ថា សាមគ្គីមានជ័យ?

សុផល ៖ បាទ?

ដានី ៖ ស្រុកសាមគ្គីមានជ័យ ។

សុផល ៖ សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។

ដានី ៖ ចុះអ៊ំឪពុកអ៊ំឈ្មោះអីដែរ?

សុផល ៖ អូ! គាត់ស្លាប់យូរហើយ សួរទាំងអស់សួរអស់ដល់អាចម៍ដល់នោមចឹង កូនក្តី ហេតុផលនឹងចង់សួរម៉េចៗអត់យល់?

ដានី ៖ បាទ! ដើម្បីយើងសរសេរជាប្រវត្តិអ៊ំ ដូចថាយើងសរសេរដាក់ទស្សនាវដ្តី ចឹងហើយបានថាដូចថាតាំងពីក្មេងអ៊ំរស់នៅភូមិណា ឪពុកឈ្មោះអី ចឹងអ៊ំចេញដូចថាតាំងពីក្មេង អ៊ំរៀនដល់ថ្នាក់ប៉ុន្មាន ចេញតស៊ូពីឆ្នាំណាអីចឹង ។

សុផល ៖ ខ្ញុំដូចចង់ខ្ជិលឲ្យសរសេរប្រវត្តិរឿងរ៉ាវ ខ្ជិលវា ។

អ្នកជិតខាង ៖ ដល់សួរចឹងបានដឹងថាអ៊ំនៅស្រុកណាៗ ។

សុផល ៖ ហ្នឹងហើយបើនិយាយពីគំនិត យើងចាស់ហើយវាខ្ជិលចង់និយាយប្រវត្តិរឿងរ៉ាវអី ចង់និយាយហេតុផលអី ។

ដានី ៖ ចេះអ៊ំកាលពីក្មេងៗអ៊ំរៀនសូត្រអីដល់ថ្នាក់ណាដែរ?

សុផល ៖ ខ្ញុំថ្នាក់ទី៦ ។

ដានី ៖ កាលនឹងថ្នាក់ទី៦ យើងរៀនប៉ុន្មានឆ្នាំបានដល់ថ្នាក់ទី៦?

សុផល ៖ អានឹងយើងគិតមើលតាំងពីថ្នាក់ទី១២ ១១ហើយ ថ្នាក់ទី១០ ទី៩ អានឹងវាចាប់ផ្ដើមថ្នាក់ទី១២មុនមកៗថយមកទី១១ ១០ហើយបាន៩ៗ ៨ៗ ៧ ៦ៗ អានឹងបើយើងនិយាយរួមថាអនុវិទ្យាល័យ ។ មិនយើងឥឡូវទេ ថ្នាក់ទី១ ទី២ ទី៣រហូតដល់ថ្នាក់ទី១២នោះណា ។

ដានី ៖ កាលនឹងសាលាណាដែរ កាលអ៊ំនៅស្រុកកំណើតពាម?

សុផល ៖ ខ្ញុំរៀនវាច្រើបដែរ រៀននៅសាលាពាមនឹង តែខ្ញុំមករៀននៅខត្តមទេពប្រណម វត្តត្រាំងនៅគៀកខដុន្ត ។ ស្គាល់ទេ?

ដានី ៖ បាទៗ ។

សុផល ៖ ហើយខ្ញុំមករៀននៅនឹង ។ ហើយបួសរៀន ខ្ញុំបួសៗទៅរៀននៅនឹងទៀត ។

ដានី ៖ អូ!បួសដែរ បានបួសនៅណា?

សុផល ៖ ខ្ញុំបួសនៅវត្តទេពខត្តមនោះ តែខ្ញុំទៅរៀននៅខដុន្ត ។

ដានី ៖ អ៊ំបួសបានប៉ុន្មានឆ្នាំដែរ?

សុផល ៖ បួសបានតិចដែរ បានប្រហែល៣វស្សា ។

ដានី ៖ បួសបាន៣វស្សា?

សុផល ៖ តែដល់ញោមស្លាប់ទៅក៏ត្រូវសឹកវិញ ខ្ញុំអត់ព្រមសឹកទេ រៀនឲ្យចប់ចុងចប់ដើមគំនិតណាំ ខ្ញុំយល់ថាបើសិនជាយើងរៀន សំខាន់បំផុតគំនិតដែលថាចង់រៀនៗឲ្យបានថា ធ្វើម៉េចផ្លូវលោកផ្លូវធម៌ឲ្យវាយល់ទាំងអស់ អានឹងជាគំនិត ។

ដានី ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ?

សុផល ៖ បងប្អូនច្រើនដែរ ៧ដែរ ។

ដានី ៖ បងប្អូន៧នាក់?

សុផល ៖ ស្លាប់អស់នៅសល់៣នាក់ ។

ដានី ៖ អ៊ំទីប៉ុន្មាន?

សុផល ៖ ខ្ញុំទី៦ ។

ដានី ៖ ទី៦ ជិតពៅគេដែរ?

សុផល ៖ បាទ!

ដានី ៖ ចឹងមានបងៗគាត់ធំៗ?

សុផល ៖ បាទ! គាត់ធំអស់ហើយ ។

ដានី ៖ ដល់ពេលបងធំៗហើយ បានឪពុកអ៊ំគាត់ខូច?

សុផល ៖ បាទ!

ដានី ៖ តែម្តាយគាត់នៅទេ?

សុផល ៖ ម្តាយស្លាប់អស់ ម្តាយខ្ញុំទើបនឹងស្លាប់ឆ្នាំ៧៩ ។

ដានី ៖ ទើបស្លាប់?

សុផល ៖ បាទ!

ដានី ៖ ចឹងអ៊ំដល់ពេលរៀនចប់ហើយបានអ៊ំបួសលោក? ១

សុផល ៖ បាទៗ ។

ដានី ៖ បួសបាន៣វស្សាហើយអ៊ំមករៀនវិញ សឹកមក?

សុផល ៖ ខ្ញុំបួសរៀនហើយ បួស សឹកហើយបានមកជំនាន់ក្រោយមកកាលនឹងជំនាន់គេអ៊ូអាល់ទៅតស៊ូនយោបាយ ។ សម្តេចសីហនុគាត់ប្រកាសឲ្យកូនចៅចូលព្រៃម៉ាគីម៉ាគា ។ ឆ្នាំ៧០នឹងក៏ខ្ញុំចូលមកព្រៃនឹងគេមក ។

ដានី ៖ ចឹងអ៊ំចូលឆ្នាំ៧០?

សុផល ៖ បាទ!

ដានី ៖ ចុះកាលពីមុនឆ្នាំ៧០ អ៊ំដូចថាធ្លាប់បានទាក់ទងអីយើងដូចថាតស៊ូអីពីនៅក្នុង?

សុផល ៖ ខ្ញុំកូនសិស្ស ។

ដានី ៖ កាលនឹងយើងអត់ទាន់បានតស៊ូអីគេទេ?

សុផល ៖ នៅតស៊ូ រឿងបញ្ហាកន្លងមកវាអាចមានខ្លះ តែគ្រាន់វាថាមិនទាន់ជាខ្សែចង្កាក់អីយើងនៅស្រាលនៅមិនទាន់បំពាក់នយោបាយអី ។ ប៉ុន្តែគ្រាន់យល់ថាយើងបញ្ហាចក្រពត្តិអាមេរិចបញ្ហាថាលន់ នល់ធ្វើរដ្ឋប្រហារទៅពីដើមសម្តេចសីហនុគាត់ ។ ដូចជានេះទៅ ដល់ចឹងទៅលន់ នល់ធ្វើរដ្ឋប្រហារ អាមេរិចកាំងវាចាប់ផ្តើមធ្វើរដ្ឋប្រហារសម្តេចសីហនុហើយ ឲ្យលន់នល់ធ្វើរដ្ឋប្រហារនឹង បានលន់ នល់ទៅជាអាយ៉ងរបស់អាមេរិចហើយ ។ នឹងហើយបានជាចលនាយើងចាប់ផ្តើម យើងមិនត្រូវប្រឆាំងជាមួយអាមេរិច អានឹងដើមចម ដើមហេតុដំបូងនឹងបញ្ហាមូលហេតុមកពីអាមេរិចទេ ចាក់រុកឲ្យខ្មែរយើងធ្វើសង្គ្រាម ។ អានឹងជាហេតុផលដំបូងចឹង អានឹងយើងមិនដឹងទេ គ្រាន់ថាយើងពិនិត្យស្រាវជ្រាវហេតុដំបូងវាចឹង ។

ដានី ៖ តែពេលនឹងយើងចូល ដូចថាមានចលនាតស៊ូដើម្បីដូចថាប្រឆាំងអាមេរិច កាលនឹងអ៊ំចូលទៅខាងណាទៅ ចូលព្រៃ?

សុផល ៖ ខ្ញុំចូលមកព្រៃជាមួយខាងកម្ពុជាប្រជាធិបតេយ្យ ។

ដានី ៖ កាលនឹងគ្នាច្រើនទេ?

សុផល ៖ យើងជំនាន់នឹងវាមិនច្រើនប៉ុន្មានទេ ដូចថាវាមានទៅតាមគ្រប់តាមខេត្ត ។ ម៉ាខេត្តមាន ប្រហែលជារៀបចំជាទ័ពនឹងប្រហែលជាកងវរៈ ។

ដានី ៖ កងវរៈ?

សុផល ៖ ម៉ាខេត្តៗ ។

ដានី ៖ យើងចូលភ្លាម យើងចូលជាកងទ័ពម៉ង ជាកងទ័ព ជាកងវរៈម៉ង?

សុផល ៖ មុនដំបូងមានជា យើងរៀបចំមិនមែនជាកងវរៈទាំងអស់ទេ តែរៀបចំចឹងទៅកម្លាំងបាន ច្រើនចឹងទៅ យើងរៀបចំបង្កើតចេញជាទ័ព ។

ដានី ៖ ចឹងអ៊ំដំបូង យើងចេញតស៊ូចេញពីស្រុកកំណើតមកម៉ង?

សុផល ៖ បាទ! ចេញពីស្រុកកំណើត ។

ដានី ៖ អានឹងចេញ យើងចូលទៅក្នុងព្រៃហើយ?

សុផល ៖ បាទ!

ដានី ៖ ក្នុងព្រៃខាងណាទៅ?

សុផល ៖ ព្រៃនឹងវានៅភ្នំដំរាយ កំពង់ឆ្នាំងៗវាជាដែនដីរបស់អ្នកតស៊ូហើយ ភ្នំដំរាយ ។

ដានី ៖ គេហៅភ្នំនរាយណ៍?

សុផល ៖ ភ្នំដំរាយ ភ្នំឱរ៉ាល់ ភ្នំគេហៅភ្នំភ្លល់ៗគេមានភ្នំមួយទៀត ភ្នំខាងត្បូងទៅភ្នំពីស ភ្នំព្រះ អានឹងចាប់តាំងពីភ្នំខាងត្បូងទៅខាងគេអានឹងគេនៅភ្នំដំរីរមាលអីទៅ ខាងតាកែវ ។

ដានី ៖ ហើយកាលនឹងយើងចូលជាមួយពីណាខ្លះទៅគ្នាច្រើន អ៊ំនៅចាំឈ្មោះដូចថាយើងចូលទៅ ស្របាលៗគ្នានឹង?

សុផល ៖ អឺ! ស្លាប់អស់ច្រើនណាស់ នៅសល់តិចតួចណាស់ ។

ដានី ៖ អ៊ំចាំឈ្មោះខ្លះទេ ចាំឈ្មោះដូចថាយើងចូលជាមួយគ្នា ដូចថាចលនាដែលយើងចូលទៅ?

សុផល ៖ ម៉ាជំនាន់ដែលខ្ញុំមកនឹង ចូលនឹង ឧទាហរណ៍មានបញ្ហាគេបំភ័យយើង បើថាបើយើងមិន ចេញមក គឺគេចាប់យើងហើយ ។ កាលនឹងពួកលន់ នល់នឹង ចាប់វះពោះៗប្រកស្មោម៉ង កាលនឹង ។ ចាប់វ៉ៃធ្វើបាបប្រជាជនធ្លាប់វះពោះ លើកមុនមានទាហានមានអីចាំបាញ់ចាំអី ចឹង យើងអត់ ។ ទោះបីជាជួបយើងក៏អត់បាញ់ដែរ អត់ទាន់ធ្វើទេណា តែដល់ពេលព្រឹត្តិ ការណ៍ក្រោយមកចាប់ផ្ដើមបាញ់សម្លាប់ៗបានកើតនៅមិនបានក៏នាំគ្នាចេញមក ប្រុងអត់ ចេញមកទេ តែដល់ពេលគេធ្វើសកម្មភាពខាងយោធាចឹង យើងខ្លាចស្លាប់ដែរ ក៏ចេញមក

អានឹងហេតុផលចឹងទេ ។ ឲ្យដឹងថាមកតស៊ូដើម្បីអីៗអត់យល់ទេ ដើម្បីគេចខ្លួនលផុតពីការស្លាប់ប៉ុននឹងទេ ។

ដានី ៖ ចុះប៉ុន្តែហេតុផលអីដូចថាយើងមិនអាចយើងនៅស្ងៀម លន់ នល់ គេមកវះពោះ ទាល់តែយើងប្រហែលជាមានចលនាអីប្រឆាំងជាមួយគេ បានគេវះពោះអីយើង?

សុផល ៖ អានឹងមានៗគោលការណ៍គេ ការអប់រំការណែនាំនយោបាយ គេអប់រំរឿងបញ្ហាយើងតស៊ូ ។

ដានី ៖ ចុះដូចថាកាលនឹង ដូចជិនាន់អ៊ំ ខាងណាគេដូចថាមកអប់រំ មកណែនាំ?

សុផល ៖ ហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន ។

ដានី ៖ គាត់ចុះមកណែនាំអប់រំតែម្តង?

សុផល ៖ បាទ!

ដានី ៖ កាលនឹងដូចថាហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន នៅក្នុងភូមិរបស់អ៊ំ ឬគាត់នៅក្នុងព្រៃពេលដែលចុះមកអប់រំ?

សុផល ៖ គាត់ដើរចូលតាមភូមិឃុំ ។ ពីក្នុងបើយើងនិយាយពីចលនានឹងវាពិបាកនិយាយវាវែងឆ្ងាយ បើកាលណាយើងនិយាយវាវែងឆ្ងាយពេក ។ ឆ្ងាយៗឧទាហរណ៍ថាក្នុងប្រភេទខ្ញុំឧទាហរណ៍ទេណា ឧទាហរណ៍ថាក្មួយឯងធ្វើម៉ាឃុំ ប្អូននោះធ្វើម៉ាឃុំ ដល់ចឹងរកក្មេង២-៣នាក់ទៅមកការពារទៅ ដើរជាមួយអានេះប៉ុនធ្វើការម្តុំគ្នាទៅ បែកភូមិបែកឃុំ បែកស្រុកធ្វើទៅ ។ ដល់ពេលចឹងទៅវាមានកម្លាំងអីទៅស្គាល់អីចឹងទៅក៏ជូនដំណើរជូនអីចឹងទេ មិនមែនជារឿងមានអីគោលគំនិតបេះចុះនោះទេ ។ ថាយើងមិនទាន់មានគំនិតអីច្បាស់លាស់ទេ ។

ដានី ៖ ចុះកាលជំនាន់នឹង អ៊ំអ្នកនៅភូមិអ៊ំនឹងដែលទៅដូចថាយើងធ្វើការជាមួយហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផននឹង ។ អ៊ំ មានពីណាទៀត?

សុផល ៖ ភាគច្រើនគឺស្លាប់ តែនៅអ្នកនៅខាងបាំងរលក ។

ដានី ៖ គាត់នៅខាងស្រុកដែរ ។

សុផល ៖ បាទ! នៅស្រុកដែរ ។

ដានី ៖ បាទ! ហើយពីណាទៀត ។ អ្នកស្លាប់ក៏ដោយ ខ្ញុំគ្រាន់តែចង់ដឹងឈ្មោះគាត់ ជាការចងចាំ? ពីណាខ្លះ?

សុផល ៖ អឺ! ស្លាប់អស់ច្រើនណាស់ក្មួយ ស្លាប់នឹងតាំងពីកាលនឹងកើតម៉ាជំនាន់នឹងមាននៅតាមស្រុកដល់ពេលយើងចេញមកជួបគ្នាមក យកមកពីខាងកំពង់ស្ពឺខ្លះ មកពីខាងគ្រប់ខេត្តទាំងអស់គេមកជួបគ្នាស្គាល់គ្នាទៅ វាពិបាកនឹងនិយាយដែរ ភ្លេចតាភ្លេចអីគេអស់ខ្លះ ។

ដានី ៖ បាទ! ប៉ុន្តែឈ្មោះ?

សុផល ៖ ឈ្មោះ ចននឹងស្លាប់ហើយ ។

ដានី ៖ ចន គាត់អ្នកស្រុកណា ចន?

សុផល ៖ ចន គាត់នៅខាងថ្មមុំ កំពង់ពោធិ៍ ភូមិនឹងវាខ្ញុំកំពង់ឆ្នាំងកំពង់ស្ពឺវាព្រំប្រទល់ជាប់គ្នាអាស៊ីង យើងខាង...វាជាប់គ្នា ។ ដល់ចឹងពេលយើងនៅកំលោះៗ យើងដើរលេងចូលឆ្នាំជាមួយគ្នា ជាមិត្តភក្តិ ។

ដានី ៖ អ៊ំស្គាល់អ៊ំពូចទេ?

សុផល ៖ ពូចណា?

ដានី ៖ ពូច គាត់នៅខាងកំពង់ស្ពឺដែរ ប៉ុន្តែនៅជិតវត្តតាំងខ្មៅ ។

សុផល ៖ ពូច?

ដានី ៖ ពូច ឥឡូវគាត់នៅអន្លង់វែង ។ ឥឡូវគាត់ក្រុមប្រឹក្សាឃុំថ្នាត នៅអន្លង់វែង ។ ឪពុកគាត់ ឈ្មោះ ប៉ោ នោះ ។ គាត់នៅជាប់ខាងស្រុកអ៊ំដែរ ។

សុផល ៖ ពូចនឹង ខ្ញុំស្គាល់ហើយ តែឥឡូវវាភ្លេចដឹតាគាត់មិនដឹងឈ្មោះអីទៀត ពូចនឹង ខ្ញុំស្គាល់ដែរ បែកគ្នាយូរទៅ វាដូចជាភ្លេច ។

ដានី ៖ ចុះអ៊ំអាន ស្គាល់អ៊ំអានដែរ?

សុផល ៖ ស្គាល់តើ ។

ដានី ៖ ហើយខ្ញុំធ្លាប់ទៅជួបគាត់នៅកំរៀងដែរ ។

សុផល ៖ ចឹង ។ អាននៅស្រុកជិតគ្នា ។

ដានី ៖ គាត់នៅស្រុកកំណើតនៅចន្ទ្រាលពាល ។

សុផល ៖ នៅចន្ទ្រាលពាល ។

ដានី ៖ អ៊ំស្គាល់គ្នាតាំងពីសម័យយើង ដូចថាយើងជួបអប់រំជាមួយហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន នឹងដែរ?

សុផល ៖ ស្គាល់ម៉ាជិនាន់នឹងខ្ញុំស្គាល់ តាំងពីចុះអ្នកស្រុកអ្នកភូមិជិតគ្នា គាត់នៅចន្ទ្រាលពាល ខ្ញុំនៅ ស្រែអណ្តូងជិតគ្នាៗខាងលិច-កើត ។

ដានី ៖ ខ្ញុំធ្លាប់ទៅដល់នឹងដែរ វត្តស្រែអណ្តូង?

សុផល ៖ ចឹង ខ្ញុំនៅនឹង ។

ដានី ៖ នៅជិតវត្តនឹងម៉េង?

សុផល ៖ នៅ ។

ដានី ៖ ផ្ទះនៅមុខវត្ត ហើយក៏?

សុផល ៖ បាទ! នៅខាងលិចវត្ត ។

ដានី ៖ ខ្ញុំចូលទៅខាងក្នុងវត្ត ។

សុផល ៖ ចូលក្នុង?

ដានី ៖ បាទ!

សុផល ៖ ប្អូនអ៊ំអាននឹងឈ្មោះ វ៉ាត សុវ៉ាត ។

ដានី ៖ ឈ្មោះអីគេ ឈ្មោះវ៉ា?

សុផល ៖ វ៉ាត សុវ៉ាត ។

ដានី ៖ ចឹងការអ៊ំតស៊ូ ដែលយើងតស៊ូ យើងរៀនសូត្រដើរជាមួយ កាលជំនាន់នឹង ជំនាន់អ៊ំពូច អ៊ំអាន អ៊ំអ៊ីនឹងស្របាលៗគ្នានឹង ដំណាលៗគ្នា ហើយក៏មុនក្រោយ?

សុផល ៖ អត់ទេ គាត់ចាស់ខ្ញុំក្មេង ជំនាន់នោះខ្ញុំនៅក្រោយទៅទៀត ។ ខ្ញុំម៉ាសេរីក្រោយទៀត ។

ដានី ៖ សេរីក្រោយទៀត?

សុផល ៖ បាទ!

ដានី ៖ ក្រោយអ៊ំពូច ហើយក៏ដំណាលអំពូច?

សុផល ៖ ក្រោយៗ ។

ដានី ៖ ក្រោយទៀត?

សុផល ៖ បាទ! ក្រោយអ៊ំអាននឹងទៀត ។

ដានី ៖ អ៊ំអាន គាត់ចេញតស៊ូតាំងពីឆ្នាំ៦០ជាង?

សុផល ៖ តាមមើលចលនានឹងគឺមិនមែនទេ ខ្លះចាស់តែខ្លួនមែន ប៉ុន្តែក្របខណ្ឌដូចថាពេលការងារគឺ គាត់ចុះអមស្រុងនឹងគ្នាដែរនឹង អានឹងចឹង ។

ដានី ៖ ចឹងអ៊ំនៅតស៊ូ នៅកន្លែងដូចថាអ៊ំមានប្រសាសន៍ម៉េច អ៊ំនៅតាមជួរភ្នំដំរាយចឹង?

សុផល ៖ បាទ!

ដានី ៖ ដំរាយនៅខាងឱរាល់រហូតដល់ពេលណាទៅ?

សុផល ៖ នៅយូរដែរ ខ្ញុំនៅម៉ាក្រុមរបស់ខ្ញុំរៀបចំម៉ាក្រុម ។ ខ្ញុំម៉ាក្រុមនឹងនៅការពារហ្វ៊ូ យន់ ។

ដានី ៖ ការពារហ្វ៊ូ យន់?

សុផល ៖ បាទ!

ដានី ៖ ការពារពីឆ្នាំណាដល់ឆ្នាំណា?

សុផល ៖ ការពាររហូតដល់យើងតាំងពីឆ្នាំ៧០មករហូតដល់មកយើងឆ្នាំ៧២ ។

ដានី ៖ ដល់ឆ្នាំ៧២?

សុផល ៖ បាទ! ៧២បានខ្ញុំចុះមកកាន់ទ័ព វ៉ៃនៅ.....។

ដានី ៖ កាន់ទ័ពនៅណាអ៊ំ?

សុផល ៖ នៅកំពង់ឆ្នាំងដែរ ។

ដានី ៖ កាន់ទ័ពនៅកំពង់ឆ្នាំង?

សុផល ៖ បាទ!

ដានី ៖ នៅកន្លែងណាពីព្រោះកំពង់ឆ្នាំង បើយើងនៅខាងកំពង់ឆ្នាំងខាងទាហានទេ តែយើងកាន់ទ័ព?

សុផល ៖ យើងនៅទ័ព យើងឈរនៅខេត្ត តែបានអីចូលស្រុកមក និយាយពីជនបទមក ។ កាលនឹងមិនដឹងគោលការណ៍ថាយកជនបទហ៊ុំព័ទ្ធទីក្រុង ន័យវាចឹងមិនមែនយើងមកលេងនឹងក្រុងទេ ។

ដានី ៖ ពីព្រោះយើងខាងក្រុងពួកខាងទាហាន បើនៅខាងអ៊ំនេះ ប៉ុន្តែយើងកាន់ខាងកំពង់ឆ្នាំង តែយើងដូចថា?

សុផល ៖ បាទ! មុខព្រួញយើងមកនឹង ។

ដានី ៖ កាលនឹងទ័ពអ៊ំគ្នាច្រើនទេ?

សុផល ៖ ទ័ព រៀបចំម៉ាកងវរៈ ។

ដានី ៖ ម៉ាកងវរៈៗសេនាតូច?

សុផល ៖ វរៈសេនាតូច ។

ដានី ៖ អានឹងឆ្នាំ៧២យើងចេញដុតពី បន្ទាប់ពីការពារហ្វូ យន់មក?

សុផល ៖ ៧១ ។

ដានី ៖ ម៉ាកងវរៈគ្នាប៉ុន្មាននាក់?

សុផល ៖ កងវរៈ គ្នា៣០០ជាង ។

ដានី ៖ ៣០០នាក់ជាង?

សុផល ៖ ជិត៤០០ ។

ដានី ៖ ចឹងកងវរៈដែលដូចថាអ៊ំដឹកនាំនឹង ដូចថាកងទ័ពនឹងកូនកងទ័ពនឹងយើងដើរឃោសនាកូនចៅដូចថាអ្នកស្រុកអ្នកភូមិឲ្យចូលកងទ័ព ឬក៏ពួកគាត់ស្ម័គ្រចិត្តមកចូល?

សុផល ៖ អត់មានយើង មិនឃោសនាអីចឹងៗទេ សំខាន់បំផុត យើងនិយាយពីមាគ៌ាកាលនឹង មាគ៌ានយោបាយកាលនឹងអប់រំថា សំខាន់យើងចលនាចុះទៅជួយធ្វើការងារប្រជាជនៗ ជួយ

ស្ទួន ជួយដកអីផ្សេងៗទៅការងារអី ធ្វូនស្រាលអ៊ីៗគឺជួយប្រជាជន។ ចលនាឲ្យឃើញបញ្ហាដូចថាទៅបម្រើប្រជាជន គឺដោយគ្មានលក្ខខណ្ឌមានន័យចឹង ធ្វើការងារប្រជាជនដោយគ្មានលក្ខខណ្ឌ។ ដល់ចឹងខ្ញុំធ្វើការងារជួយគាត់ទៅ ហូរហែរសព្វបែបយ៉ាង។ គាត់អត់អី មានអី យើងដោះស្រាយឲ្យគាត់ទៅ អ្នកអត់បាយ អត់ទឹកមានអត់លុយអត់កាក យើងចេះចាត់ចែងទ្រព្យសម្បត្តិដោយសារយើងរក មានលុយមានកាកអីខ្ញុំជួយ អានឹងតាមការណែនាំមក យើងអនុវត្តតាមគោលការណ៍នឹង។ តែសំខាន់បំផុត គឺចង់និយាយថា បើសិនជាយើងអ្នកណាធ្វើមិនត្រឹមត្រូវ ធ្វើមិនល្អ គឺអត់ឲ្យធ្វើនៅក្នុងនឹងទេ ឲ្យនៅបង្រៀនដើរជាមួយកម្មាភិបាល អត់ឲ្យនៅជាប់ទេ។ ដើរជាមួយកម្មាភិបាលៗឲ្យកម្មាភិបាលអប់រំណែនាំទៅ។

ដានី ៖ កម្មាភិបាលកាលនឹងហ៊ូ នឹម, ហ៊ូ យន់, និងខៀវ សំផន ហើយពីណាទៀត?

សុផល ៖ អានឹងមិនមែន ជាប្រភេទគេខាងលើ។

ដានី ៖ ចុះប្រភេទកម្មាភិបាលដែលអ៊ំមានប្រសាសន៍មិញ?

សុផល ៖ អានឹងកម្មាភិបាលគេរៀបចំមានភូមិ មានឃុំ មានស្រុកចឹងទៅ។

អ្នកជិតខាង ៖ និយាយចឹង ចាប់ពីប្រធានក្រុមមកគេហៅកម្មាភិបាលសម័យនោះ។

សុផល ៖ បាទ! អានោះយើងចង់និយាយចឹង ឧទាហរណ៍ថាឥឡូវ ឧទាហរណ៍ថាក្មួយឲ្យទទួលនឹងភូមិនេះមួយ។ ឧទាហរណ៍ភូមិតាកែវចឹង នេះភូមិស្រែអណ្តូងចឹង នេះភូមិចង្វាលរាល ភូមិព្រៃស្វាយចឹងទៅ ចែកគ្នា។ ហើយនៅក្នុងភូមិនឹងមាន ឧទាហរណ៍ថាប្អូននឹងធ្វើឃុំ ដល់ចឹងគេហៅមកឲ្យធ្វើការគេជួយសំរួលសិក្សាចេញទៅធ្វើការវិញ ពិសោធន៍ ដកការធ្វើការងារដកពិសោធន៍ចឹងទៅ ធ្វើការងាររីកចំរើនអីខ្លះ ធ្វើការមានប៉ះពាល់ប្រជាជន។ កាលនឹងចង់និយាយថា លើកឡើងកាលនឹង បើពិន័យយើងត្រូវតែ បើទ័ព សូម្បីតែដេសមួយសរសៃ គឺមិនឲ្យប៉ះពាល់ដល់ប្រជាជនទេ។ មិនមែនត្រឹមតែរឿងរបស់របរ សូម្បីតែដេស ឬម្ទេះម៉ាដើម អំបោះមួយសរសៃ គឺអត់ឲ្យប៉ះពាល់ប្រជាជន អានឹងជាវិន័យ ជាច្បាប់។

ដានី ៖ អានឹងច្បាប់នឹងដូចថាអ៊ំៗដូចជាហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន គាត់មកបង្រៀនទ្រឹស្តីនឹង ឬក៏គេមានឯកសារគេសរសេរ សម្រាប់ឲ្យយើងណែនាំទៅកម្មាភិបាលយុវជនទៅ?

សុផល ៖ អានឹងជាច្បាប់ គេមានចងក្រងជាច្បាប់ពិភាក្សាក្នុងន័យនឹងយើងអត់ដឹង។ យើងមិនដឹងទេ តែគ្រាន់ថា ដូចជាដូចប្អូនចឹង ជាខ្ញុំចឹងយកពាក្យណែនាំពីនឹងមក យកមកណែនាំក្រោមទៀត។ អានឹងណែនាំតៗចឹង។

ដានី ៖ ណែនាំតៗ?

សុផល ៖ បាទ! ណែនាំគ្នា ។

ដានី ៖ ចឹងកាលកងទ័ព ដែលអ៊ំមានម៉ាវរៈសេនាតូចនឹង កាលនឹងដូចតាម៉េត គាត់នៅជាមួយអ៊ំដែរ ហើយក៏ផ្សេង?

សុផល ៖ ម៉េតណា?

ដានី ៖ ស៊ូ ម៉េត?

សុផល ៖ ស៊ូ ម៉េត នៅជាមួយគ្នាដែរ ។

ដានី ៖ នៅជាមួយគ្នា ក្នុងវរនឹងជាមួយគ្នា?

សុផល ៖ បាទ!

ដានី ៖ កាលនឹងគាត់ធំជាងអ៊ំហើយក៏?

សុផល ៖ គាត់គ្រប់គ្រងធំជាងខ្ញុំ ។

ដានី ៖ គាត់គ្រប់គ្រងនៅវរៈហ្នឹង?

សុផល ៖ គាត់គ្រប់គ្រងកងពល ។

ដានី ៖ កងពល ពេលនៅខេត្តប៉ៃកកំពង់ឆ្នាំងនឹង អ៊ំអ្នកគ្រប់គ្រងទេ?

សុផល ៖ មិនមែនទេ បញ្ជាគ្រប់គ្រងកំពង់ឆ្នាំងវាមានកងច្រើន ។

ដានី ៖ កងច្រើន?

សុផល ៖ បាទ! កងច្រើន ។

ដានី ៖ មានប៉ុន្មានកងទៅ?

សុផល ៖ មានបីយើងនិយាយមក ក្នុងកងកម្លាំងប្រដាប់អាវុធនឹងវាមាន៣-៤ ២-៣ កងវរៈនឹង ។

ដានី ៖ កងវរៈរបស់អ៊ំមួយ របស់ពីណាទៀត បើតាមអ៊ំចាំ?

សុផល ៖ កងវរៈមានកងវរៈមុនដំបូង១២០ ១៣០ ១៤០ ១៥០ ១៦០ អានេះគេចែកចឹងមាន១៨០ លេខចេះលេខចាំរៀបចំកងវរៈមួយៗវាមានកងចឹង ហើយវាមានកង៣០១ ៣០២ចឹងទៀតទៅ ។ វារៀបចំ ឧទាហរណ៍ថាក្នុងម៉ា៣វរៈសេនាតូច វាមានម៉ាវរៈសេនាធំ ។ ៣វរៈសេនាធំ បានម៉ាកងពល អានឹងចឹង ហើយរៀបចំចឹង យើងមិនមែននៅជាប់គ្នាទាំងអស់ទេ ចែកមុខសញ្ញាណា ឧទាហរណ៍ថាក្មួយឯងទទួលជាអនុសេនាតូចមួយ ហើយចុះម៉ាស្រុក ។ ខ្ញុំថាបើឈ្មោះខ្ញុំបានអនុសេនាតូចចុះទៅម៉ាស្រុកទៀត ។

ដានី ៖ ចុះទៅរៀងៗខ្លួន?

សុផល : ចុះទៅរៀនខ្លួន ចុះទៅធ្វើការនឹងៗមិនមែនធ្វើការតែយោធាទេ នយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច ការទូតទំនាក់ទំនង ។ ការទូត យើងចង់និយាយថាដើរគ្រប់ទាំង៥ វិស័យទាំង៥ នេះគឺដើរឲ្យគ្រប់ ។ ការទូតនិយាយរឿងអី ការទូតសំខាន់បំផុត បើយើងនិយាយមកថា មិនមែនទាក់ទងនឹងបរទេសទេ ។ ចង់និយាយថា ទាក់ទងឧទាហរណ៍ថា ពីផ្ទះមួយទៅផ្ទះមួយ ទំនាក់ទំនងផ្សារភ្ជាប់ សាមគ្គីពីស្រុកមួយទៅស្រុកទៅស្រុកមួយទៅតភ្ជាប់ទៅទៀត ។

ដានី : ដល់ពេលនេះយើងរកសេដ្ឋកិច្ចក្នុងនឹងយើងរកស្បៀងផ្គត់ផ្គង់ខ្លួនឯងទៀត?

សុផល : បាទ! ផ្គត់ផ្គង់ ។

ដានី : ដល់ពេលនយោបាយ យើងត្រូវចេះបញ្ចុះបញ្ចូល យើងចេះនៅ?

សុផល : នយោបាយតាមមើល តាមយើងធ្វើមិញគឺថា គោលការណ៍ទី១គឺធ្វើអំពើល្អៗនឹងហើយវាចេញជាសកម្មភាពកម្លាំងចូលច្រើន ធ្វើអំពើល្អនឹងគេទៅ នេះធ្វើល្អ ។ តែគ្រាន់នយោបាយជ្រៅរាក់យើងមិនទាន់យល់ទេ ដឹងថាឲ្យធ្វើអំពើល្អ ដឹងថាធ្វើអំពើល្អនឹង អានេះន័យចឹង ។

ដានី : ចឹងកាលជំនាន់អឹដូចថាពីឆ្នាំ៧១នឹងមានកងពលហើយ?

សុផល : កាលនឹងនែក! មានរៀបចំជាមេខាងលើវាមានហើយ តែគ្រាន់ថាយើងចែកជាចេញអាផ្នែកៗ ចុះធ្វើការតាមផ្នែកទេ ។

អ្នកជិតខាង : អង្គការខាងលើមាន អង្គការខាងក្រោមអត់មានទេ តែ៧១ ៧២នៅទេ ទាល់តែ៧៣បានចេញជា ។

សុផល : បាទ! នៅទេ មិនទាន់មានទេ ។ មិនទាន់មានទេ តែគ្រាន់រៀបចំជាប្រព័ន្ធ បើគេមាន ប៉ុន្តែគ្រាន់តែចែកៗជាសាខារបស់គេៗចែកគ្រប់គ្រងតាមនឹង ។ ប៉ុន្តែដោយឡែកជា គេហៅថាកងឯករាជ្យ គេហៅថាអនុសេនាតូចឯករាជ្យ អនុសេនាធំឯករាជ្យ ។ ដូនកាលចាត់តាំងអនុសេនាតូចឯករាជ្យម៉ាស្រុកនឹងបណ្តោយ ។ ឯករាជ្យចង់និយាយថា អ៊ីទាំងអស់យើងចាត់ចែង ប៉ុន្តែយើងមកមានបញ្ហាអ៊ីទំនាក់ទំនងជាមួយខាងលើ ។

ដានី : ជាមួយកងពលខាងលើ?

សុផល : បាទ!

ដានី : ចឹងអឹ នៅធ្វើការ នៅកំពង់ឆ្នាំង ពីឆ្នាំ៧១រហូតដល់ពេលណាទៅ?

សុផល : ខ្ញុំធ្វើមកឆ្នាំ៧១ ៧២ ៧៣ ៧៤ ៧៥ ជាប់រហូតទើបតែរំដោះភ្នំពេញ ។

ដានី : ចឹងពេលនឹង ពេលដែលឆ្នាំ៧១យើងមិនទាន់ជាទាហាន វៃអីជាទ្រង់ទ្រាយធំហើយប្អូនៅ?

សុផល ៖ នៅទេ ។

ដានី ៖ នៅទេ?

សុផល ៖ ឆ្នាំ៧០ ៧១នឹងយើងវ៉ៃតាមប៉ុស្តិ៍ ។

ដានី ៖ តាមប៉ុស្តិ៍?

សុផល ៖ បាទ! យើងវ៉ៃខទាហរណ៍ថាក្នុងភូមិចឹងភូមិអន្លង់រាបមានប៉ុស្តិ៍មួយៗមានទាហាន ប៉ូលីស នៅម៉ុំនឹងរៀបចំអ្នកឯងវ៉ៃយកប៉ុស្តិ៍នឹងឲ្យបាន ។ ដោយឡែកប៉ុស្តិ៍នៅណានៅអមលាំង នៅត្រពាំងដោនឹងទៅ វ៉ៃផ្តាច់កាលនឹងប៉ុស្តិ៍មិនមានច្រើនទេ ចលនាគេរៀបចំប្រព័ន្ធកាលនឹងមានប៉ូលីសប្រចាំប៉ុស្តិ៍ ហើយមានទាហានចូលម៉ុំនឹង ។ ហើយកងអន្តរាគមន៍គេគឺចុះទៅម្តងៗ ទៅបន្ទាយលង្វែកទៅ ។

ដានី ៖ បន្ទាយលង្វែក?

សុផល ៖ បាទ!

ដានី ៖ ចឹងពេលដែលកាលនឹងគេហៅ ដូចថាគេហៅសង្រ្គាមឈ្លបនៅឡើយទេ?

សុផល ៖ បាទ! សង្រ្គាមឈ្លប ។

ដានី ៖ គេធ្វើឈ្លបពី៧០ ៧១ សង្រ្គាមឈ្លប?

សុផល ៖ អត់ទល់មុខទេ សង្រ្គាមឈ្លប ។

ដានី ៖ ចុះដល់ពេលចាប់ពី៧២ យើងចាប់ផ្តើមមានបើកជាទ្រង់ទ្រាយធំ យើងវ៉ៃអីទល់មុខអី ចាប់ផ្តើម?

សុផល ៖ មានៗ ។

ដានី ៖ មានហើយ?

សុផល ៖ ឆ្នាំ៧០នឹង គេចាប់ផ្តើមគេបង្ហាត់បង្រៀនវ៉ៃពិសេស ។ វ៉ៃរូបភាពវ៉ៃនឹង វាមានវ៉ៃពិសេស វ៉ៃពិសេស វ៉ៃកាំភ្លើងធំ វ៉ៃបង្រ្គប់ វ៉ៃចលនា ។

ដានី ៖ ចុះដូចអីដូចអី យើងបានរៀនយុត្តសាស្រ្តពីសង្រ្គាមនឹង មានរៀនអី មានអ្នកបង្រៀនមានអីដែរ យើងបានដកស្រង់បទពិសោធន៍ខ្លួនហើយដឹកនាំ?

សុផល ៖ យើងមានដែរ ។

ដានី ៖ យើងមានដែរ?

សុផល ៖ បាទ!

ដានី ៖ កាលនឹងយើងរៀននៅណា?

សុផល ៖ យើងរៀននឹង មានគេបង្រៀនមក ខ្មែរៗគ្នាយើងមកបង្រៀន ។

ដានី ៖ ខ្មែរមកពីណា?

សុផល ៖ ខ្មែរនឹងគេយកទៅបង្ហាត់ទៅបង្រៀនណាទេ យើងមិនដឹង តែគ្រាន់ថាខ្មែរគ្នាឯងទៅរៀនចឹង យល់បញ្ហាចឹងមកធ្វើការទៅ ចុះដាប់រៀន។

ដានី ៖ មិនមែនពួកដូចថាខ្មែរយើងដែលគាត់ហៅថាខ្មែរខាងជើង?

សុផល ៖ យៀកមិញ?

ដានី ៖ បាទ! ដូចថាពួកដូចថាកាលពេលយើងបែក យើងបានឯករាជ្យឆ្នាំ៥៣ ៥៤ ពួកនៅនឹង ហើយត្រឡប់មកបង្ហាត់បង្រៀនយើង អត់ទេ?

សុផល ៖ អត់ទេ។

ដានី ៖ អត់ទេ យើងបង្រៀនខ្លួនយើង?

សុផល ៖ បាទ!

ដានី ៖ ចឹងអីរៀនយុត្តិសាស្ត្រនឹង យើងរៀនធ្វើបណ្ដើរយើងរៀនបណ្ដើរ ឬក៏យើងរៀនហើយ បានយើងចុះទៅធ្វើ?

សុផល ៖ អានឹងច្បាប់ដំបូងគេមិនឲ្យយើងទៅ មិនទាន់ចេះដំឡូងមូលយើងទៅធ្វើទេ គេរៀនសិន។ ទី១ រៀននយោបាយ។ចង់និយាយថា ពាក្យនយោបាយយើងយល់ពាក្យនយោបាយម៉ា ម៉ាត់នឹង អប់រំដើម្បីធ្វើម៉េចឲ្យអ្នកឯងហ៊ានចូលកាណុង អានឹងវាសំខាន់នយោបាយអី អា នឹងជារឿងបញ្ហា យើងនិយាយនយោបាយម៉ាម៉ាត់នឹងទូលាយណាស់ អប់រំនយោបាយ យោធា។ យោធាគេបង្ហាត់ពីរឿងបញ្ហាបច្ចេកទេស។ ការរៀននឹង ខ្ញុំក៏រៀនហាត់។ ពិសេស ដល់ម្នាក់។គឺទាមទារទៅវៃពិសេស វាអត់មានគ្រោះថ្នាក់កម្លាំង។

ដានី ៖ វៃពិសេសម៉េច អានឹងវៃម៉េចបានអត់គ្រោះថ្នាក់កម្លាំង?

សុផល ៖ វៃពិសេស ប្អូនឯងមានតែទីតាំងទេ មាន១០០នាក់នៅនឹង ខ្ញុំយកតែ១០នាក់ទៅវៃតែ ១០នាក់ទេ វៃឲ្យឈ្នះ។

ដានី ៖ វៃម៉េច?

សុផល ៖ អានឹងវៃពិសេស វៃបែក។មុខសញ្ញាគ្នា។ យើងឧទាហរណ៍ថាចូលទៅបែក ក្មួយឯងពេល ដែលទៅមុននឹងវៃទីតាំងនឹង ឧទាហរណ៍ថាឥឡូវប្រគល់ជារកិច្ចថាក្មួយឯងទៅវៃទីតាំងនឹងម៉ា កន្លែង ដំណឹងគេថាទាហាន១០០នាក់។ បើចឹងត្រូវប្រើកម្លាំងទៅពិនិត្យទីតាំងនឹង គេរាយ ការណ៍មក១០០ យើងជឿគេថា១០០មែនអត់អត់ទាន់ច្បាស់ទេ។

ដានី ៖ ទៅពិនិត្យខ្លួនឯង?

សុផល ៈ បាទ! ទៅពិនិត្យខ្លួនឯង ហើយពិនិត្យហើយមានម្តងយើងពិនិត្យមើលក្តាប់តាមប្រជាជន ពិនិត្យទៅមើលផ្ទាល់ សកម្មភាពទាហានដើរគេដើរយ៉ាងម៉េចៗ មានមនុស្សប៉ុន្មាន អាគ្នុង បន្ទាយប៉ុន្មាន ដល់យើងយកពត៌មានបាន យើងដឹងថាទាហានអត់ដល់១០០ទេ ចុះពី ១០០ៗ បើចឹងយើងយកកម្លាំង១០នាក់ទៅវ៉ៃទេៗ កម្លាំង១០ទៅវៃៗយ៉ាងម៉េច មុននឹងវ៉ៃតើមានកាំភ្លើងអីខ្លះ កាំភ្លើង៨០ កាលនឹងអត់មាន៨២ មាន៨១មីលីម៉ែត្រមាន ខ្ទុសេត(១២)អាកន្ទង់ចុះនឹងប៉ុន្មានដើម មាន៦០មីលីម៉ែត្រប៉ុន្មានដើម យើងចាប់ផ្តើមទៅ ចលនាទៅពិនិត្យទីតាំងបានអស់ហើយ មានរបងអីរបងលួស មានផ្ទះប៉ុន្មានអីប៉ុន្មានចែកទី បញ្ជាការនៅកន្លែងណា ហូរម៉េចអីម៉េច កាំភ្លើងធំដាក់កន្លែងណាៗ លូនចូលលើកក្រោយ យើងជញ្ជូនចូល យកដីទៅដាក់នៅក្នុងកាណុងកាំភ្លើង៨១មីលីម៉ែត្រៗ

ដានី ៈ ដាក់ដើម្បីកុំឲ្យបាញ់កើត?

សុផល ៈ បាទ! ដាក់កុំឲ្យបាញ់កើតៗ ហើយកាំភ្លើងម៉ាស៊ីននឹង យើងចូលទៅ ធ្វើសកម្មភាពដំបូងៗ ចូលហើយយើងបោក ឬក៏ យើងចាប់អាអ្នកកាន់កាំភ្លើងធំៗ វាបាញ់វិញ ចាប់ក្លឹបម៉ង់ៗ ក្លួយឯងទៅនៅនឹង បើថាខ្ញុំលូនទៅចាប់ឲ្យអគ្គុយមើលខ្ញុំៗ ខ្ញុំចូលទៅចាប់ជើងឥឡូវ មើល ខ្ញុំអត់ឃើញទេៗ

ដានី ៈ យើងលូនទៅពេលយប់ ហើយពេលម៉េច?

សុផល ៈ យប់ក៏បាន ថ្ងៃក៏បាន ស្ថានណាក៏ដោយ ឲ្យតែពេលគេវ៉ៃពេលយប់ តែថ្ងៃវាពិបាកយើង អាចមើលឃើញដានជើងបានព្រោះចូល តែពេលយប់ច្របាច់ពិលមិនច្របាច់ពិលមើលទៅ កេះជើងបណ្តោយៗ

ដានី ៈ ចុះអ៊ីដល់ពេលយើងចាប់ផ្តើមរៀបចំជាកងពលជាអីមានរចនាសម្ព័ន្ធអីត្រឹមត្រូវចាប់ផ្តើមពី ឆ្នាំណា?

សុផល ៈ ដូចជាក្បែរ៧២ដែរ នៅចុង៧២ៗ

ដានី ៈ ចុះអ៊ឺយើងចាប់ផ្តើមរៀបចំជាកងពលជាអី មានរចនាសម្ព័ន្ធអីត្រឹមត្រូវ ចាប់ពីឆ្នាំណា?

សុផល ៈ ប្រហែល៧២ដែរ ចុង៧២ៗ

ដានី ៈ ចុង៧២?

សុផល ៈ បាទ!

ដានី ៈ កាលនឹងយើងរៀបចំកងពល កាលនឹងលេខកងពលលេខប៉ុន្មាន?

សុផល ៈ កងពលទី១ៗ

ដានី ៈ កងពលទី១ កងពលនឹង កងពលរបស់ភូមិភាគ ឬក៏របស់យ៉ាងម៉េច?

សុផល ៈ	កងពលភូមិភាគ ។

ដានី ៈ	ភូមិភាគណា ភូមិភាគនិរតី ឬក៏បស្ចឹម?

សុផល ៈ	បស្ចឹម ។

ដានី ៈ	បស្ចឹម?

សុផល ៈ	បាទ!

ដានី ៈ	កាលនឹងចាប់ពី៧២ទៅយើងរៀបចំជាកងពល?

សុផល ៈ	បាទ!

ដានី ៈ	ហើយកងពលផ្សេងៗទៀត មានកងពលអីច្រើនអត់?

សុផល ៈ	មានៗប្រចាំតាមភូមិភាគ ។

ដានី ៈ	ប្រចាំភូមិភាគ?

សុផល ៈ	បាទ! ដូចភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគពាយ័ព្យ មានខត្តរចឹងទៅ អានឹងវាប្រចាំភូមិភាគ កម្លាំងគេនៅនឹង ។

ដានី ៈ	ពេលឆ្នាំ៧២នឹង យើងមានរៀនជារចនាសម្ព័ន្ធជាកងពល?

សុផល ៈ	បាទ!

ដានី ៈ	កាលនឹងកងពលទី១?

សុផល ៈ	បាទ!

ដានី ៈ	គណៈកងពលមានពីណាខ្លះ មានតាម៉េតដែរ?

សុផល ៈ	ម៉េត សឿង ។

ដានី ៈ	សឿង គេហៅពេទ្យសឿងនឹង?

សុផល ៈ	បាទ!

ដានី ៈ	២នាក់ ហើយប៉ុន្មាននាក់?

សុផល ៈ	សុវ៉ាត់ ប្អូនដាត ។

ដានី ៈ	ចឹង គាត់គណៈកងពលដែរ?

សុផល ៈ	បាទ! គាត់ធ្វើខាងនយោបាយ ក្រោយមកគាត់ជាប់ទៅនៅខាងជាមួយគ្នាដែរ ដល់ពេលនេះគេដកឲ្យគេគ្រប់គ្រងណា ។

ដានី ៈ	តាម៉េត គាត់ខាងនយោបាយ ក៏ខាងអីគេ?

សុផល ៈ	នយោបាយ ។

ដានី ៈ	ដល់ពេលតាសឿង?

សុផល ៖ យោធា ។

ដានី ៖ យោធា ដល់ពេលប្អូនអ៊ំអាន ឈ្មោះ វ៉ាតមិញ គាត់ខាង?

សុផល ៖ អានឹងគេផ្លាស់ប្តូរកងទៀតទៅ រៀបចំឲ្យចូលនយោបាយ ។

ដានី ៖ ចុះវរៈកាលនឹងមាន៣វរៈសេនាធំ?

សុផល ៖ បាទ!

ដានី ៖ អ៊ំនៅក្នុងវរៈសេនាធំ ឬក៏?

សុផល ៖ កាលនឹងវាពិបាកនិយាយចេះ ខ្ញុំថាទៅជួបវរៈសេនាតូចមួយ តែគ្រាន់ថាគ្រប់កាលនឹងខ្ញុំនៅវរៈសេនាធំ ។

ដានី ៖ អ៊ំទទួលវរៈសេនាតូចមួយ ប៉ុន្តែយើងមានតួនាទីនៅវរៈសេនាធំ?

សុផល ៖ បាទ!

ដានី ៖ វរៈសេនាធំអ៊ំលេខប៉ុន្មាន?

សុផល ៖ ១៥ ។

ដានី ៖ លេខ១៥ មានប៉ុន្មានវរៈសេនាធំ កងពលទី១?

សុផល ៖ បាទ?

ដានី ៖ កងពលទី១នឹងមាន៣វរៈសេនាធំនឹង មានវរៈសេនាធំលេខ១៥ ១០ប៉ុន្មាន?

សុផល ៖ ១៦ ១៧ ។

ដានី ៖ ១៦ ១៧?

សុផល ៖ បាទ!

ដានី ៖ អ៊ំទទួល១៥ ហើយគ្រប់គ្រងម៉ាវរៈសេនាតូច?

សុផល ៖ វរៈសេនាធំ ។

ដានី ៖ ម៉ាវរៈសេនាធំ១៥?

សុផល ៖ បាទ!

ដានី ៖ ចុះ១៦?

សុផល ៖ ១៦ មានគេមួយទៀត ។

ដានី ៖ ពីណាគេ?

សុផល ៖ វ៉ុន ។

ដានី ៖ វ៉ុន គាត់ស្លាប់យូរហើយ គាត់ទើបនឹងស្លាប់?

សុផល ៖ ស្លាប់កាល៧៥ ។

ដានី ៖ ចុះ១៧?

សុផល ៖ ១៧ ផលដែល ផល១ ដើងសេក ។

ដានី ៖ បាទ?

សុផល ៖ ផលដែល ផល១ ដើងសេក ។

ដានី ៖ ផលដើងសេក ។ ឈ្មោះដូចអីដែរ ប៉ុន្តែគេដាក់ថែមគាត់ថាដើងសេក?

សុផល ៖ ផល ដើងសេក ។

ដានី ៖ ចុះអ៊ំសាននេះ គាត់មាននៅកងពលដែរអត់?

សុផល ៖ គាត់នៅកងពល នៅជាមួយបងសឿងនឹងដែរ ។

ដានី ៖ គាត់នៅជាមួយតាសឿងដែរ?

សុផល ៖ បាទ!

ដានី ៖ ចឹងគាត់នៅគណៈកងពលដែរ?

សុផល ៖ បាទ! គាត់ជាសមាជិត តែគាត់អត់សូវចេះអក្សរចេះអីទេ ។

ដានី ៖ គាត់អត់សូវចេះអក្សរ?

សុផល ៖ បាទ! គ្រាន់ថាឲ្យ......គ្រាន់ថាគាត់ចាស់ទុំ ។

ដានី ៖ ចឹងគាត់នៅក្នុងគណៈកងពល ដោយសារគាត់អត់សូវចេះអក្សរចឹង គាត់អត់សូវមានដូចថា តួនាទីអីសំខាន់?

សុផល ៖ បាទ!

ដានី ៖ ចឹងដល់ពេលយើងរៀបចំជាកងពលហើយ យើងចាប់ផ្ដើមវៃជាទ្រង់ទ្រាយធំហើយ?

សុផល ៖ បាទ! ទ្រង់ទ្រាយធំ ។

ដានី ៖ យើងវៃចាប់ផ្ដើមវៃទៅណាខ្លះទៅកាលនឹង ដល់ពេលយើងចាប់ផ្ដើមមានកងពល យើងវៃមុខព្រួញយ៉ាងម៉េច កងពលទី១?

សុផល ៖ អានឹងស្រេចលើខាងលើហោ តែគ្រាន់ថាភារកិច្ចខ្ញុំវៃបុកទៅផាកទៅកំពង់ឆ្នាំង ផាកទៅកំពង់ស្ពឺ ទៅក្រុងភ្នំពេញ ។

ដានី ៖ យើងវៃបុកបែងចែកជា៣?

សុផល ៖ បាទ!

ដានី ៖ មានខ្លះយើងវៃបុកចូលមកកំពង់ឆ្នាំង មួយបុកទៅខាងកំពង់ស្ពឺ មួយបុកទៅភ្នំពេញវិញ?

សុផល ៖ បាទ!

ដានី ៖ មុខព្រួញយើងចាប់ពីទិសណាខ្លះ គេចាប់ពីទិសខាងណា ដល់ពេលកាលនឹងយើងមិនមានមុខព្រួញថាដូចថាយើងចាប់ផ្ដើសកម្មភាពពីត្រឹមណាដល់ត្រឹមណា?

សុផល ៖ សកម្មភាពៗនឹងដល់យូរពេកទៅខ្ញុំពិបាកនិយាយ ខ្ញុំម៉ាជួរថ្នល់ជាតិលេខ៥មកទល់នែក! ផ្លូវយើងក្រុករពោធិ៍សាត់ បុកទៅទួលលាភចឹងទៅ ធ្លាក់ទៅវ៉ៃធ្លាក់ទៅដោះក្រញូរអីចឹងទៅ។ វ៉ៃជួនកាលធ្លាក់ទៅ អានឹងស្រេចតែលើទៅខាងឲ្យជួយសហការនឹងទៅ វ៉ៃទៅកំពង់សិលា។

ដានី ៖ អូ! ទៅខាងកំពង់សោម កំពង់?

សុផល ៖ បាទ! កំពង់សិលា ជួនកាលហក់ទៅជួយគេខាងនឹងទៅ គេមកជួយយើងខាងនឹង អ្នកដែលមានគេហៅថា។

ដានី ៖ មុខព្រួញអីច្បាស់លាស់ទេ?

សុផល ៖ ហ៎! គេច្បាស់លាស់ៗប៉ុន្ដែសហការ។

ដានី ៖ សហការ?

សុផល ៖ កម្លាំងដែលថាអត្ថិភាព យើងជួបម្ដុំៗណានឹងអាចជួយប្រមូលផ្ដុំចឹង។ ឧទាហរណ៍ថាឱកាសល្អនៅកន្លែងណាចឹង យើងអាចយកកម្លាំងនឹង យើងដកកងម៉ានឹង ដែលមិនខុសអីពីការរៀបចំពីដំណើរការយុត្តិសាស្ត្ររបស់សត្រូវមនឹង យើងនិយាយមិនចប់ទេ។

ដានី ៖ ប៉ុន្តែកាលនឹងដូចថា ខាងលើត្រូវដាក់ទិសដៅមកថាត្រូវវ៉ៃអីចឹង ខាងភូមិភាគ ឬក៏ខាងណាខាងមជ្ឈិម?

សុផល ៖ អានឹងខាងមជ្ឈិម គេបញ្ជាមកភូមិភាគ។

ដានី ៖ ខាងណាទៅ?

សុផល ៖ បាទ?

ដានី ៖ ខាងមជ្ឈិមពីណាគេអ្នកទទួលខាងទិសដៅ...?

សុផល ៖ មជ្ឈិមនឹងមានអ៊ីៗខាងលើ។

ដានី ៖ អ៊ីណា?

សុផល ៖ លើដឹងហើយ លើមានប៉ុន្មានរូប។

ដានី ៖ ប៉ុន្តែក្រែងអ៊ីៗគាត់មានតួនាទីផ្សេងៗគ្នា ដូចជាអ៊ីសុន សេន គាត់ខាងទ័ព?

សុផល ៖ ខាងម៉ាជួរខាងនឹងគឺមានតាម៉ុក។

ដានី ៖ តាម៉ុក?

សុផល ៖ បាទ! និរតីតាម៉ុក និរតី បស្ចឹម តាម៉ុក។

ដានី ៖ ចុះតាជូ ជេត គាត់ខាង....?

សុផល ៖ ជួន ជឿន ហៅតាម៉ុកនឹងហើយ ។

ដានី ៖ ជូ ជេតនឹង គាត់នៅជាមួយតាម៉ុក?

សុផល ៖ ឈ្មោះតាម៉ុកនឹងហើយ ។

ដានី ៖ តាម៉ុក គាត់ឈ្មោះ ជួន ជឿន? ដល់ពេលជូ ជេតៗហៅតាស៊ី?

សុផល ៖ អូ! នេះហើយស៊ី ។

ដានី ៖ ឈ្មោះបដិវត្តគាត់ហៅតាស៊ី?

សុផល ៖ ហ្នឹងហើយៗភ្លេច ខ្ញុំភ្លេច ។

ដានី ៖ តែគាត់អ្នកបញ្ជា ឬក៏ជាគណៈកងពលអ្នលវ៉ៃខាងណា?

សុផល ៖ អឺ! ឥឡូវបេះក្លួយឯងសួរចឹង វាដូចថាឆ្ងល់ថា យើងក្មេងក៏ថាបានដែរ ចង់និយាយថា បើ........មិនមែនឧទាហរណ៍ថាទទួលផែនការពីខាងលើមក រៀបចំផែនការមួយខែ ផែនការ ២ខែ ផែនការ៣ខែ ឬផែនការ១៥ថ្ងៃ កន្លះខែ ត្រូវវ៉ៃប៉ុន្មាន ត្រូវវ៉ៃទីតាំងណា ត្រូវវ៉ៃកន្លែងណាៗឲ្យបាន នឹងជាគោលការណ៍មួយដាក់ឲ្យដាច់តែម្តង ចឹងទាល់តែភូមិភាគម្ចាស់ការៗ ចាត់ចែងសមរភូមិជីវភាព ដោះស្រាយសកម្មភាពមួយៗ ។

ដានី ៖ ចុះអ៊ឹភូមិភាគបស្ចឹមនឹង យើងចាប់ផ្តើមបង្កើតតាំងពីពេលណាមក?

សុផល ៖ ឥឡូវខ្ញុំអត់ចាំអស់ដែរ គ្រាន់ថាការរៀបចំខាងលើៗវាមិនដឹងណា ថ្ងៃៗណាៗវាមិនដឹងខ្ញុំមិនដឹង ចាប់ផ្តើមដំណើរការឆ្នាំប៉ុន្មានក៏ខ្ញុំវាភ្លេចអស់ហើយ វាយូរលែងចាប់អារម្មណ៍លែងអីអស់ហើយ ។

ដានី ៖ តាំងពីមុនរដ្ឋប្រហារឆ្នាំ៧០ ឬក៏ក្រោយមកទេ?

សុផល ៖ ក្រោយ ។

ដានី ៖ ក្រោយ?

សុផល ៖ បាទ!

ដានី ៖ ក៏ដូចជាភូមិភាគនិរតីអីមានតាំងពីមុនម៉េច អត់ទេក្រោយមក?

សុផល ៖ ភូមិភាគនិរតី ភូមិភាគបស្ចឹមវាមានតាំងពីដំបូងមក ដែលយើងចារជាភូមិភាគ តាំងពីជំនាន់បើយើងនិយាយមក គេចែកតំបន់តាំងពីនឹងយើងហៅថាបក្សសម្ព័ន្ធឥណ្ឌូលចិន គេហៅបក្សពលករវៀតណាមៗ កាលនឹងបកឥណ្ឌូចិននឹងវាធំពេក ។ ហើយចឹងបានវៀតណាមនឹងគេដាក់ឲ្យយើងដកខ្លួនចេញពីបក្សឥណ្ឌូចិននឹង ព្រោះមានយួន ខ្មែរ ឡាវ ប្រទេស៣នឹងវាជាឥណ្ឌូចិន ។ ហើយចឹងបក្សឥណ្ឌូចិន វាធំយ៉ាងណាគ្រប់គ្រងនៅឥណ្ឌូចិន ។ ដល់ចឹង....រកបក្សពលករ ។ អាចឹងរឿងរ៉ាវនឹងវាវែងពេក ចុះខ្ញុំបេះនិយាយវា ។

ដានី ៖ បាទ! ពីព្រោះអានឹងវានិយាយពីបក្សនេះវិញ វាឆ្ងាយ ។

សុផល ៖ យើងមិនយល់អស់ ។

ដានី ៖ បាទ!ពីព្រោះវាមានពាក់ព័ន្ធវៀតណាម ពាក់ព័ន្ធឡាវ ពាក់ព័ន្ធខ្មែរយើង ។ ហើយមានតាំងពីឆ្នាំយូរហើយ ។

សុផល ៖ បាទ! យើងមិនយល់ ចាំមិនអស់ ប្រវត្តិសាស្ត្រចាំមិនអស់ទេ ប៉ុន្តែគ្រាន់និយាយថាយើងដឹងពេលណា ។

ដានី ៖ ប៉ុន្តែខ្ញុំរៀងច្រឡំតិចអ៊ំ បើទាក់ទងនឹងភូមិភាគបស្ចឹម និងភូមិភាគពិសេស ពីព្រោះដូចកាលនឹងការធ្វើចលនាដូចថាទិសដៅ ដូចនៅជាមួយគ្នាម៉េច ភូមិភាគពិសេស?

សុផល ៖ អត់ ខុសគ្នា ។

ដានី ៖ ខុសគ្នា?

សុផល ៖ បាទ!

ដានី ៖ ភូមិភាគពិសេស កន្លែងណាវិញ?

សុផល ៖ ភូមិភាគពិសេ គឺចូលនៅក្នុងខេត្តកណ្តាល គឺ ។

ដានី ៖ ខេត្តកណ្តាលវិញ?

សុផល ៖ បាទ!

ដានី ៖ តើមានកំពង់ស្ពឺខ្លះណាអត់?

សុផល ៖ ខេត្តកណ្តាលគេចាប់ចូល ក្នុងខេត្តកណ្តាលនឹងវាបែងចែកកំណត់ថា ឧទាហរណ៍ថាទីក្រុងភ្នំពេញគេចុចមកចំនុចត្រង់ណាខ្លះៗ អានឹងក្នុងទីក្រុងភ្នំពេញ អានឹងគេហៅខេត្តកណ្តាលភូមិភាគពិសេសៗនឹង លើគេកំណត់ទេ ថាផ្លូវចាប់ពីភូមិអី ខ្ញុំឧទាហរណ៍ថាយកពីភូមិតាកែវមកនេះមក ភូមិភាគពិសេស ។ ស្រេចគេកំណត់ទេ គេចុចយកឲ្យគ្នាងាយស្រួលស្តាប់ទេ មិនទាន់ថាប្រាកដនិយមទេ តែចេះចុះទេ ។

ដានី ៖ បើតាមខ្ញុំធ្លាប់ជួបពូៗ ដែលខ្ញុំធ្លាប់សម្ភាសន៍គាត់ ដូចថាភូមិភាគពិសេសកងពលនឹងមួយដូចថាវ៉ៃចូលមកតាមពោធិ៍ចិនតុងដែរ ។ ដូចថាយើងខាងភូមិភាគ អ៊ឹកងពលទី១នេះ តាមពោធិ៍ចិនតុងដែរ មើលទៅខ្ញុំច្រឡំគ្នាមិនដឹងថាគេបែងចែងម៉េច?

សុផល ៖ អត់ទេ! វាចែកចេះ ឧទាហរណ៍ថា ភូមិភាគ ពិសេស គេតួនាទីរបស់គេៗគ្រប់គ្រងម្តុំនឹងគេមើលគេវ៉ៃ ភូមិភាគពិសេស ។ ប៉ុន្តែដែលថាវ៉ៃ ដូចថាភូមិភាគបស្ចឹមនឹង គេបុកចូលទៅមុខព្រួញរបស់គេ គេទៅចឹងទៅ ទៅចូលភូមិភាគពិសេសដែរ ។

ដានី ៖ ចូលទៅស្របគ្នាទៅ?

សុផល ៖ វាចូលទៅ ចុះអានេះអស់ហើយ យើងមិនបុកចូលទៅក្នុងទៀត ន័យវាចឹង បើបុកសំដៅបំផុតគឺសំខាន់គឺភ្នំពេញ មុខពីនោះមកដូចគ្នាដែរ ។ របៀបចែកចឹងទេ មិនមែនប្រកាន់ថាភូមិភាគពិសេស គេគ្រាន់តែចែកភូមិភាគពិសេស សម្រាប់ដែលយល់ថាតួនាទីតំបន់របស់ឯង គេហៅថាចែកSectorគ្នា ។

ដានី ៖ អ៊ំមួយទៀត ដូចថាពេលដែលយើងវ៉ៃចូលភ្នំពេញ កងពលកាលនឹង ដូចជាសម្ភារៈដូចជាគ្រាប់រមសេវអីយ៉ាងម៉េច ពេលដែលវ៉ៃនឹងយើងមានគ្រប់គ្រាន់ដែរ នៅពេលដែលយើងចាប់ផ្ដើមវ៉ៃចូលទីក្រុងភ្នំពេញ ។ ដូចជាគ្រាប់ ដូចជាស្បៀង កម្លាំងទ័ពអី?

សុផល ៖ យើងមិនមែនគ្រប់គ្រាន់ទេ នេះជាគោលការណ៍ខាងលើប្រាប់មកថា *«វ៉ៃពីខ្មាំង យកអាវុធពីខ្មាំងទៅវ៉ៃខ្មាំងវិញនេះជាគោលការណ៍ទី១ ។ វ៉ៃយកស្បៀងខ្មាំង ដើម្បីផ្ដល់ឲ្យកងទ័ពយើងទៅវ៉ៃនឹងវិញនេះ ។ វ៉ៃទីតាំងយកអង្ករ»* មនុស្សវាមិនស៊ីបាយ បើវ៉ៃកន្លែងនឹងយើងបានអង្ករស៊ីកន្លែងនឹង អត់មានចំណាយលុយកាក់ទៅទិញអង្ករទេ ។ ឯងចង់បានហូប ឧទាហរណ៍ថាឥឡូវខ្ញុំជាកូននេះ បងជាមកសុំអង្ករខ្ញុំ ។ ឯងចង់បានអង្ករឲ្យទ័ព ទៅវ៉ៃទីតាំង រៀបចំកម្លាំងវ៉ៃភ្លាមបានអង្ករស៊ីហើយ ។ ន័យចឹង ។

ដានី ៖ ចឹងយើងវ៉ៃអស់ខ្លាំងយកមក?

សុផល ៖ បាទ!

ដានី ៖ បានន័យថាយើង?

អ្នកជិតខាង ៖ វ៉ៃឈ្នះទេបានយកមក វ៉ៃចាញ់គេយកមកធ្វើអី ។

សុផល ៖ អានឹងយើងនិយាយមាគ៌ាចឹង គឺទៅៗរៀនចំកន្លែងនឹង អានឹងយើងដោះស្រាយឲ្យ អានឹងយើងឲ្យទៅវ៉ៃសិន ប៉ុន្ដែអង្ករយើងឲ្យ មិនមែនទេ ជាគោលការណ៍ណែនាំចឹង ។

ដានី ៖ ចុះដូចអាវុធអីយើង អាវុធធ្ងន់ស្រាល អាវុធធន់ធ្ងន់ ដូចជារថក្រោះអីមានគ្រប់គ្រាន់ពេលដែលយើងវ៉ៃ?

សុផល ៖ អត់មានទេរថក្រោះ ។

ដានី ៖ អត់មានរថក្រោះទេ?

សុផល ៖ រថក្រោះយើងអត់មានទេ មានតែអាវុធប្រឆាំងរថក្រោះ ។

ដានី ៖ ចុះអ៊ំកាលយើងវ៉ៃនឹង យើងវ៉ៃម៉េចយើងវ៉ៃស៊ុតស្មាញណាស់ ក៏យើងវ៉ៃស្រួលៗដែរ?

សុផល ៖ អើយ! និយាយពីដើមមិញស៊ុតស្មាញគេធ្វើនិយាយមិនបានទេ អានឹងយើងវ៉ៃលេងៗម៉េចនឹងឈ្នះ ។

ដានី : ក្រែងលរថា ពួកលន់ នល់ពួកនឹងដូចថាទាហានមិនសូវជាហៅថាលុតដំខ្លាំង ហើយមិនសូវស៊ូដូចខាងយើង គ្រាន់តែទៅប្រាំរ៉ៃៗរត់អស់ហើយអីចឹង?

សុផល : មិនមែនទេ តស៊ូ វាចង់និយាយថា ច្បាប់យុត្តិសាស្ត្រ សង្គ្រាមបច្ចេកទេស គឺមានដូចគ្នា បច្ចេកទេសមានដូចគ្នា ប៉ុន្តែស៊ីសងនៅលើស្មារតីសហការ គេហៅថា "នយោបាយជាមូលដ្ឋាន គោលជំហរសតិអារម្មណ៍ជាកត្តាកំណត់ ឯអាវុធការកើនវាជាបញ្ហាបច្ចេកទេស" ។

ដានី : ចុះអំពេលដែលតែនឹង អំចុះជាប់ជាមួយកូនទាហានដែរ ឬក៏យើងនៅទីតាំងដូចថាយើងជាអ្នកយុត្តិសាស្ត្រ តែគេចឹងក៏យើងចូលទៅជាមួយកូនទាហានបញ្ជាទៅ?

សុផល : ទៅ ។

ដានី : ទៅដល់ត្រឹមណា ឧបមាថាយើងទាហានខ្សែត្រៀមចឹង យុត្តិសាស្ត្រដែលត្រូវចាំ?

សុផល : នៅជាមួយកម្លាំង ។

ដានី : នៅជាប់កម្លាំង?

សុផល : បាទ! ឧទាហរណ៍ថាផ្លូវ ខ្ញុំឧទាហរណ៍ប្អូនឯងរៀបចំខ្សែត្រៀមចង់ឲ្យគេរៀបចំខ្សែត្រៀម បើយើងមិនរៀបចំចាត់ចែង ថាផ្លូវរៀបចំយកកងទៅដាក់នោះ កងរៀបចំបេះ រៀបចំវិធីតែយ៉ាងម៉េច យើងបំពាក់ខ្សែត្រៀមយ៉ាងម៉េច ទៅរៀបចំៗកម្លាំងនេះដាក់មកនេះ កម្លាំងនៅនេះ ។ យើងទៅរៀបចំយើងនៅជាប់នៅនឹង នៅប្រឡោះកណ្ដាលនឹងនៅចាំមើលអ្នកណាណែម៉េច យើងដោះស្រាយ ជំនួយបន្ថែមខ្វះខាតអី គេហៅកម្លាំងនេះ អត់ឲ្យខ្វាត់ពីខ្សែត្រៀមទេ ។ បើកម្លាំងឃ្លាតពីខ្សែត្រៀម វាមានបញ្ហាឧបសគ្គ២ ទី១ យើងបញ្ជាទ័ពអត់បាន, ប៉ុន្តែទី២ អន្តរាគមន៍កាំភ្លើងធំជាន់ខាងក្រោយខ្លាំង ទី៣ កាប៉ាល់ហោះ ចឹងនៅគៀក អត់អីទេ ។

ដានី : ប៉ុន្តែគណៈកងពលអីយើងផ្ញើ ចុះមកបញ្ជាដូចអំដែរ ឬក៏អត់ទេ?

សុផល : មានខាងបញ្ជាការគេមក ។

ដានី : បញ្ជាការគេមក?

សុផល : បាទ!

ដានី : ខាងយោធា?

សុផល : បាទ! ខាងយោធា ។

ដានី : ខាងយោធា គេចុះមកផ្ទាល់?

សុផល : ចុះមក ខ្ញុំរៀបចំចូលមកពីគ្រោះគ្នា តែអានឹងមានប្រព័ន្ធទាក់ទងខាងគេអូ គេមានរៀបចំ ។

ដានី : បើសិនអំវិញ អំនៅភាគច្រើនឲ្យតែតែអំនៅក្នុងចាំ?

សុផល ៖ ខ្ញុំអត់ដែលនៅប្រយោលទេ ។

ដានី ៖ អត់ដែលនៅប្រយោលទេ?

សុផល ៖ បាទ! បើនៅប្រយោលទេ វាមានបញ្ហាច្រើនណាស់ អត់អាចយកឈ្នះបានទេ ។

ដានី ៖ តែខាងលន់ លន់ គេអាចលើកនៅយោលដែរ ឬក៏គេចុះមក?

សុផល ៖ លន់ នល់ អត់ដឹងរឿងគេ តែគេនិយាយមករឿងប្រយោល ។

ដានី ៖ ព្រោះបើនិយាយពីអាថ៌ុធខាងលន់ នល់ទំនើបជាងយើង ។

សុផល ៖ ទំនើបជាង ។

ដានី ៖ បាទ! គេមាបនរថក្រោះគេមានយន្តហោះ គេមានអីទៀត?

សុផល ៖ បាទ! ទំនើបជាង ។

ដានី ៖ តែវៃ អត់ឈ្នះយើង?

សុផល ៖ មានទំនើប យើងយកអាទំនើបរបស់គេមកប្រើវិញ អានឹងវាចឹង យូរៗទំនើបដូចគ្នា ។

ដានី ៖ យើងវៃដណ្តើម ដល់ពេលយើងវៃទៅដណ្តើមបាន យើងយកនឹងទៅបាញ់យូរៗ?

សុផល ៖ ទំនើបដូចគ្នា ប៉ុន្តែលន់ នល់ មានទំនើប យើងក៏មានទំនើបដែរ អានឹងហេតុផលចឹង ។

ដានី ៖ ចុះអីតាំងពីអី ដូចថាតាំងពីយើងតស៊ូកង៏ទ័ពអីមកអីអត់ដែលមានគ្រូវប្ចសអី?

សុផល ៖ អត់ទេ ។

ដានី ៖ អត់ទេ?

សុផល ៖ គ្រូវតិចដូច.... ។

ដានី ៖ អឺមានអីការពារខ្លួន ឬយ៉ាងម៉េច អានឹងគិតថាយើងមានដូចថាយើងមានអីដើម្បីការពារខ្លួន ........នៅពេលយើងធ្វើសង្រ្គាម?

សុផល ៖ បើខ្ញុំពិនិត្យពីរឿងបញ្ហាការពារខ្លួននឹង យើងថាមានក៏បាន យើងថាការធ្វើអំពើល្អ ដូចគេហៅថាទេវតា ម្ចាស់ទឹកម្ចាស់ដីថែរក្សាព្រៃភ្នំក្រោមថ្មនឹងជួយថែរក្សា ។

ដានី ៖ ពេលដែលយើងទៅវៃយើងមាននឹកគុណ?

សុផល ៖ សំខាន់បំផុតយើងនិយាយថាអំពើល្អ នឹកគុណអីចឹងទៅអំពើល្អៗម៉ាម៉ាត់មក យើងនិយាយម្ចាស់ទឹកម្ចាស់ដីថែរក្សាព្រៃភ្នំក្រោមថ្មនេះ យើងគឺថាខ្ញុំមានហេតុផល បើនិយាយតាមចាស់ៗពីដើមនឹងមកណា ព្រោះដូចថាខ្ញុំវាមាន..........ផ្សេងៗដូច.............. ។

ដានី ៖ មានអីគេអានឹង ដូចយើងមានអីកាលនឹង?

សុផល ៖ វ៉ាសំណុំ ។

ដានី ៖ វ៉ាសំណុង គង់សំណុំ?

សុផល ៖ បាទ! គន់សំណុំអីនឹង ខ្ញុំវាមានអានឹង ។

ដានី ៖ អានឹងយើងមានពីកំនើត?

សុផល ៖ ហ្នឹងពីកំណើត ។

ដានី ៖ ដល់ចឹងយើងទៅចឹង ដូចថាមានបញ្ហាអីដូចគេឲ្យប្រឋ្ធរមុន?

សុផល ៖ បាទ! ប្រឋ្ធរមុន ប្រហែលជាខ្ញុំទៅតំរង់ជួរវៀន៣ ៤ ៥ជួរចឹង ។ ខ្ញុំតំរង់រួចហើយ ខ្ញុំដើរមើលៗ ឃើញអ្នកណាមុខគ្រៀម ខ្ញុំទាញដៃចេញ ហើយមិនស្តាប់ខ្ញុំឯងនឹងត្រូវរបួសៗ ឬក៏ស្លាប់បណ្តោយ អានឹងហេតុផល ។

ដានី ៖ អានេះអុំតាមចំណាំមើលម៉ង មើលទៅទឹកមុខមើលថា?

សុផល ៖ អានេះខ្ញុំមិនមែនមើលអីទេ ខ្ញុំមើលថាសំខាន់គឺខ្ញុំរៀនទស្សនវិជ្ជា ទស្សនវិទូ រៀនមើលមនុស្ស សំលឹងមើលថាមនុស្សនឹងវាអាចគ្នាមានអារម្មណ៍ខ្លាច អារម្មណ៍ភ័យខ្ញុំអត់ឲ្យទៅទេ ចឹងការវៃអីផ្សេងៗមិនសូវមានគ្រោះថ្នាក់នៅអន្តភាពទេ ។

ដានី ៖ អុំមួយទៀតទាក់ទងរឿងដូចថា អុំជាមេបញ្ជាការចឹង យើងវិន័យទាហានដូចថាក្នុងវិន័យទាហានកងទ័ព វិន័យកងទ័ពអី យើងដាក់បទបញ្ជាវិន័យអីយ៉ាងម៉េច?

សុផល ៖ វិន័យច្បាប់វិន័យចង់និយាយថា គ្មានអីគេហៅថាសីលធម៌១២ប្រការរបស់យុទ្ធជន ម្យ៉ាងសីលធម៌ ទៅកន្លែងណាឲ្យប្រជាជនស្រឡាញ់ ។ ហើយរឿងបញ្ហាការវៃ ការស្អប់រឿងជាសត្រូវៗ បើថាយើងថាជាខ្មាំងចុះ ប្រយុទ្ធជាមួយយើងហៅថាខ្មាំងហើយ ។ ហើយរឿងខ្មាំងសត្រូវ យើងដាច់ខាត ចង់និយាយចឹង ។

ដានី ៖ យើងដាច់ខាត?

សុផល ៖ បាទ! ប៉ុន្តែយើងឃើញមួយទៀតចេះ យើងនិយាយថា យើងបែងចែកពីបញ្ហាទំនាស់ៗ ត្រូវបែងចែកឲ្យដាច់ ។ មួយទំនាស់បដិបក្ស មួយទំនាស់បន្ទាប់បន្សំ ។ ទំនាស់បដិបក្សទំនាស់ស្លាប់រស់ ។ ហើយទំនាស់បន្ទាប់បន្សំជាទំនាស់ផ្ទៃក្នុង ទំនាស់យើងឈ្លោះប្រកែកគ្នាអីម៉េច សាមគ្គីគ្នាឲ្យបាន ។

ដានី ៖ អានឹងហើយគេហៅទំនាស់?

សុផល ៖ ទំនាស់ផ្ទៃក្នុង យើងសម្របសម្រួលគ្នាទៅ ដោះស្រាយគ្នាទោះបីមានបញ្ហាអីចានក្នុងរាវរដើនវន្តុំគ្នា ។ ចឹងធម្មតាអន្តភាពមួយវាមានការឈ្លោះប្រកែកគ្នាយើងសម្រួលទៅ អានេះជាបញ្ហា មិនមែនជាកត្តាធំដុំទេ ។ កត្តាធំដុំយើងសំខាន់បំផុតគឺ បញ្ហាទំនាស់បដិបក្សអ្នកណាដើម្បីយើងយកជ័យជំនះ ។

ដានី ៖ តែមួយទៀតដូចថាវិន័យផ្ទៃក្នុង ហៅថាវិន័យផ្ទៃក្នុង បើសិនជាកងទ័ពធ្វើខុសពីវិន័យ ខុសពីអី យើងត្រូវដាក់ទណ្ឌកម្មដាក់អីយ៉ាងម៉េចខ្លះទៅអានឹង?

សុផល ៖ វាមានចេះ វិន័យទណ្ឌកម្មអត់មានអីទេ យើងអប់រំ ។

ដានី ៖ យើងអប់រំ?

សុផល ៖ បាទ! អប់រំ អត់មានទណ្ឌកម្មជាប់គុកជាប់ច្រវាក់អីទេ ហើយបើសិនថាអ្នកនឹងអត់អនុវត្តបាន យើងឲ្យមកនៅក្រោយ អត់ឲ្យមកនៅនឹងទ័ពទេ ។

ដានី ៖ អត់នៅកងទ័ពទេ?

សុផល ៖ បាទ!

ដានី ៖ ពេលដែលយើងច្បាំងគ្នានឹង ពេលសង្គ្រាមនឹង?

សុផល ៖ ពេលសង្គ្រាមអីក៏ដោយ បើអត់សង្គ្រាមក៏ដោយ ក៏អត់ឲ្យនៅជួរកងទ័ពទេ ។ ឲ្យនៅខាងក្រោយមក នៅបង្កបង្កើនផលធ្វើនេះធ្វើនោះជាមួយប្រជាជនមក ។

ដានី ៖ ជាមួយប្រជាជន យើងអត់ឲ្យនៅជាមួយកងទ័ព?

សុផល ៖ អត់ឲ្យកងទ័ពទេ ។

ដានី ៖ ចុះអឺដល់ពេលឆ្នាំ ខែ៣ឆ្នាំ៧៩ ពេលដែលវៃបានទីក្រុងភ្នំពេញយើងបានរំដោះហើយឆ្នាំ៧៩ ចឹងកាលនឹងដូចថាកងពលរបស់អ៊ំចូលទៅនៅកន្លែងណា ហើយយើងចាប់ផ្ដើមរៀបចំរចនាសម្ព័ន្ធសារថ្មី?

សុផល ៖ នៅលង្វែក ។

ដានី ៖ ចឹងពេលដែលអ៊ំចូលទៅដល់ទីក្រុងភ្នំពេញ ហើយនៅទីក្រុងភ្នំពេញសិនបានមកនៅលង្វែក ឬក៏មានការយ៉ាងម៉េច យើងទៅជ្រុលមក យើងមកលង្វែកវិញ ។

សុផល ៖ វាកាលនឹងចែកនៅវាមានមួយខាងអាកាសចរ ខាងកាប៉ាល់ហោះ ។

ដានី ៖ ខាងអាកាស កងទ័ពអាកាស?

សុផល ៖ កងទ័ពអាកាសគ្រប់គ្រងការពារម្ដុំនឹង ហ្នឹងម៉ាវរៈសេនាធំៗមកនៅលង្វែក ។

ដានី ៖ ៣វរៈសេនាធំ?

សុផល ៖ បាទ! ៣វរៈសេនាធំ ។

ដានី ៖ ប៉ុន្តែម៉ាវរៈសេនាធំមកទ័ពអាកាស ហើយ២ទៀត?

សុផល ៖ ២ទៀតមកនៅលង្វែក ។

ដានី ៖ មកនៅលង្វែក?

សុផល ៖ បាទ! មួយទៀតម៉ាវរៈសេនាធំទៀត នៅខាងកោះកុងៗនឹងឯង យើងចែកការងារ កម្លាំង អត់ប្រយុទ្ធបាន ធ្វើអីបានហើយនៅខាងបង្កបង្កើនផល ។

ដានី ៖ នៅណាវិញ?

សុផល ៖ ឲ្យបង្កបង្កើនផល ធ្វើស្រែ ធ្វើចំការ ។

ដានី ៖ បាទ! ប៉ុន្តែនៅម្តុំណា?

សុផល ៖ នៅតាមខេត្តមួយៗ គឺសុទ្ធតែមានស្រែ យើងទៅធ្វើស្រែធ្វើចំការអីចឹងទៅ ផ្តល់ឲ្យកងទ័ព នៅខាងមុខ ។

ដានី ៖ ចឹងដល់ពេលចឹងគណៈកងពលមិនបែងចែកគ្នា ម៉ាក្រុមនៅខាងកងទ័ពជើងអាកាស ម៉ាក្រុម នៅខាងលង្វែក ម៉ាក្រុមនៅកោះកុង ចឹងគណៈកងពលគាត់បែងចែកគ្នា?

សុផល ៖ លង្វែកណា អន្ទង់វែងឆ្ងាយណាស់ ។

ដានី ៖ អត់ទេ លង្វែក?

សុផល ៖ អូ! លង្វែក អត់ឆ្ងាយទេ យើងលេងៗ យើងមកជួបគ្នាធ្វើការ ។

ដានី ៖ ប៉ុន្តែយើងបែងចែកជាកងពល នៅកងពលដដែល ឬក៏បានម៉ាកងពលអីផ្លាស់ប្តូរ?

សុផល ៖ ដល់ក្រោយមករៀបចំផ្សេងទៀត អានឹងវារៀបចំផ្សេងទៀតណា រៀបចំកម្លាំងបញ្ចូល បន្ថែម ។

ដានី ៖ ចុះទៅខាងទ័ពអាកាសយើងមានតែម៉ាវរៈសេនាធំចឹង យើងបញ្ចូលថែមទៀត?

សុផល ៖ បាទ!

ដានី ៖ បញ្ចូលមកពីខាងណាថែមទៀតទៅ?

សុផល ៖ គ្រប់កងពល រើសគ្រប់កងពល ។

ដានី ៖ គ្រប់កងពល បានន័យថារើសពីកងពលផ្សេងៗទៀត?

សុផល ៖ បាទ!

ដានី ៖ យើងបង្កើតជាកងពលមួយថ្មីទៀត កងពលអាកាស?

សុផល ៖ បាទ!

ដានី ៖ គេហៅកងពលអីគេអានឹង?

សុផល ៖ អឺ! ផ្នែកខាងព្រលានយន្តហោះនៅពោធិ៍ចិនតុង អាកាសចរ ។

ដានី ៖ មានលេខកងពល?

សុផល ៖ អានឹងលេខណា ខ្ញុំភ្លេច គេមានៗ ។

ដានី ៖ មាន?

សុផល : បាទ! អត់ចាំ ។

ដានី : គណៈកងពលមានពីណាខ្លះ នៅយើងខាងជើងអាកាស?

សុផល : កាលនឹងម៉េត គេនៅនឹង ។

ដានី : បាទ?

សុផល : ម៉េតគេនៅនឹង ។

ដានី : អូ! តាម៉េតគាត់នៅនឹង?

សុផល : ហ្នឹងហើយ ។

ដានី : តាម៉េត ពីណាទៀត?

សុផល : ម៉េត ណាខ្លះភ្លេចហើយ វាភ្លេចៗអស់ខ្លះៗស្លាប់ខ្លះអីខ្លះទៅវាចាំ ។

ដានី : ចុះអ៊ំមកនៅខាងណាវិញ?

សុផល : ខ្ញុំ ។

ដានី : អ៊ំនៅជើងអាកាស ឬក៏មកនៅណា?

សុផល : ខ្ញុំៗកោះកុង ។

ដានី : ទៅនៅកោះកុង?

សុផល : អឺ!

ដានី : ចឹងដល់ពេលតាម៉េត គាត់ទៅខាងជើងអាកាស ដល់ពេលកងពលទី១របស់អ៊ំនេះ នៅកងពលទី១ដដែល ឬក៏យើងមានការផ្លាស់ប្តូរ?

សុផល : នៅក្នុងកងពលដដែល តែលេខជាមួយគ្នា បែកសាខាគ្នា គេហៅបែកការធ្វើការងារ ។

ដានី : អូ! បែកធ្វើការងារ?

សុផល : បាទ! តែគ្រាន់យើងរៀបចំនឹង រៀបចំនឹងកងពលនឹងវិញដដែល ។

ដានី : កងពលនៅណាវិញ?

សុផល : នេះនៅនោះ ។

ដានី : នៅកោះកុង?

សុផល : ហ្នឹងហើយ ។

ដានី : ចឹងដល់ពេលអ៊ំឆ្នាំ៧៥ អ៊ំទៅកោះកុងហើយ ឆ្នាំ៧៥?

សុផល : បាទ! កោះកុង ។

ដានី : ដល់ពេលនៅលង្វែក?

សុផល : លង្វែកខ្ញុំមកមួងម្កាល ។

ដានី ៖ មកម្តងម្កាល?

សុផល ៖ បាទ!

ដានី ៖ ចឹងដល់ពេលកងពលនៅលង្វែកនឹងនៅសល់ពីណាខ្លះទៅ?

សុផល ៖ កងពលលង្វែកនឹងវានៅឈ្មោះ រុន នោះស្លាប់ទៅ ។

ដានី ៖ បាទ! រុន ស្លាប់ អ៊ំហើយពីណាទៀត?

សុផល ៖ ខ្ញុំមានចាត់តាំងក្រោយៗទៀត ។

ដានី ៖ ចុះតាសឿង គាត់នៅដដែល ហើយក៏គាត់ផ្លាស់ទៅណា?

សុផល ៖ ហ្នឹងគាត់មកភូមិភាគយើង ។

ដានី ៖ អូ! តាសឿងមកខាងភូមិភាគនៅជាមួយតាស៊ី?

សុផល ៖ មកតាស៊ីវិញ ។

ដានី ៖ ចឹងតាសឿង គាត់ដាច់ពីកងពល?

សុផល ៖ បាទ!

ដានី ៖ ចុះអ៊ំសាន?

សុផល ៖ អ៊ំសាន គាត់នៅលង្វែក ។

ដានី ៖ នៅលង្វែក?

សុផល ៖ បាទ!

ដានី ៖ គាត់អត់មកជាមួយតាសឿងទេ?

សុផល ៖ អត់ទេ ។

ដានី ៖ តែគាត់នៅលង្វែកនឹង គាត់នៅជាបន្ទាប់បន្សំទេ គាត់មិនមែនជាគណៈកងពលអី?

សុផល ៖ បន្ទាប់បន្សំម៉េច គាត់ចាត់ចែងនៅនឹងហើយ ។

ដានី ៖ គាត់ចាត់ចែងនៅនឹង?

សុផល ៖ បាទ! ទៅខាងកាចៗមើលកសិដ្ឋាន ស្តួងដកអីក្រុមគ្រួសារយុវជនអីនឹងណា ។

ដានី ៖ ចុះនយោបាយពីអ្នកគេ ពេលដកតាសឿងមកកាន់ភូមិភាគ?

សុផល ៖ នយោបាយវា ទៅនៅកន្លែងនឹងគាត់ទាំងអស់ គាត់ដើរតួទាំងអស់ ។

ដានី ៖ អ៊ំសាន គាត់ដើរតួទាំងអស់?

សុផល ៖ ចែកចេះទៅ យូរៗគេមកម្តង ។

ដានី ៖ តែអ៊ំទិសដៅអ៊ំមកខាងកោះកុងវិញ ប៉ុន្តែយើងនៅក្នុងកងពលជាមួយគ្នាដដែល?

សុផល ៖ បាទ!

ដានី ៖ ចុះខាងនៅខាងកំពង់សោម នៅខាងដូចថាព្រៃនប់ ខាងកោះអីផ្សេងៗនឹង?

សុផល ៖ អានឹងវាមានចេះ វាមានខាងកងការពារនឹងវាមានផ្នែកវាចែកជាបរិវេណ ឬក៏ចែកជារវាងខុសគ្នា វិធានការណ៍គ្រប់គ្រងទាំងនៅខាងខ្ញុំនឹង ម៉ាដូរកោះខ្យង ជិតូវន្តចឹងទៅទល់ទៅត្បូងជាប់ទៅកោះត្រល់ ។

ដានី ៖ កោះត្រល់?

សុផល ៖ បាទ! ទៅម៉ាដូរទៅខាងកង១៦៨នឹង គេចេះៗទៅចាប់តាំងពីអាកោះថ្មី កោះសេះ ធ្លាក់ចឹងទៅ... អានឹងវាមានតួនាទីចឹងទៅ ។

ដានី ៖ ចឹងកងរបស់អ៊ីកងពលទី១នឹងរបស់ភូមិភាគទេ របស់ភូមិភាគបស្ចឹមនេះ ដល់ពេលកង១៦៨កងរបស់គេផ្សេង របស់មជ្ឈឹម?

សុផល ៖ បាទ!

ដានី ៖ ចឹងគេការពារកោះនេះចឹងទៅ?

សុផល ៖ កោះថ្មី កោះសេះ... ។

ដានី ៖ ប៉ុន្តែកងរបស់អ៊ី នៅខាងកោះដែរ កោះក្រោយៗនេះ?

សុផល ៖ កោះត្រល់ កោះខ្យង ។

ដានី ៖ កោះខ្យល់ បាទៗ ខ្ញុំស្គាល់កោះខ្យង ខ្ញុំធ្លាប់ទៅដែរ ។

សុផល ៖ ស្គាល់?

ដានី ៖ ស្គាល់ ចូលតាមអូរចំណារ ។

សុផល ៖ អឺ! អូរចំណារ អានៅ... ។

ដានី ៖ បាទៗ ខ្ញុំធ្លាប់ទៅនឹងដែរ ។ ចឹងទៅខាងកោះត្រល់អី ហើយការពីខ្ញុំមើលឯកសារ ហើយនឹង ធ្លាប់ជួបពូៗ គាត់ថាយើងការនឹងកងទ័ពយើងធ្លាប់ទៅវៃកោះត្រល់ដែរ ។ ហើយខាងកងទ័ពចាប់បានចាប់អីនឹង ខាងកងទ័ពអ៊ំទៅវៃ ហើយមិនមែនទេ?

សុផល ៖ ខាងគេខាងនោះ ។

ដានី ៖ ខាងណា?

សុផល ៖ ខាងកំពង់សោម ។

ដានី ៖ ខាងកំពង់សោមទៅវៃវិញ?

សុផល ៖ ហ្នឹងហើយ ។

ដានី ៖ ខាង១៦៨នេះ?

សុផល ៖ ហ្នឹងហើយ ។

ដានី ៖ ចុះមិនមែនកងទ័ពអាំទៅវៃទេ?

សុផល ៖ អត់ទេ ។

ដានី ៖ ប៉ុន្តែអ៊ំមានប្រសាសន៍មិញថាកងទ័ពអ៊ំនៅខាងពីកោះត្រល់មក?

សុផល ៖ នៅកោះខ្យង ។

ដានី ៖ កោះខ្យង?

សុផល ៖ បាទ! កោះខ្យង ទៅទល់ទៅកោះត្រល់ ។ តែខ្ញុំគួនាទីខ្ញុំ អាទូកខ្ញុំប៉ុន្មាន អា១២០សេសនឹង ខ្ញុំវាំងចឹង១ឲ្យទៅក្បែរកោះត្រល់....។ មើលកោះត្រល់ មើលគ្នា មុខព្រួញទៅកោះត្រល់ ដូចតែគ្នា ។

ដានី ៖ ប៉ុន្តែអត់ដែលបានវៃអីជាមួយវៀតណាម?

សុផល ៖ អត់ទេ ។

ដានី ៖ ដូចពូៗគាត់ថាយើងឡើងទៅកោះត្រល់ ថាប្រុងទៅវៃកោះត្រល់ ហើយទៅដល់នឹងវៀត ណាមចាប់បានទាំងអស់?

សុផល ៖ ចាប់បានទាំងអស់ ។

ដានី ៖ អានឹងកងពល១៦៤?

សុផល ៖ បាទ!

ដានី ៖ អ៊ំដឹងរឿងនឹងដែរ?

សុផល ៖ ជឺនឹងដឹង ខ្ញុំនៅនឹង ។

ដានី ៖ ដឹងយ៉ាងម៉េចទៅ អាយុត្តិសាស្រ្តយ៉ាងម៉េចបានទៅវៃឲ្យគេចាប់បានទាំងអស់ចឹង?

សុផល ៖ តាមមើលកម្លាំងយើងតិចដាង អានឹងមានតែចឹង ។

ដានី ៖ តែវាយ៉ាងម៉េច បានឲ្យយើងចូលទៅឲ្យគេចាប់ យើងមិនវៃពីចំងាយវៃអី?

សុផល ៖ អានេះយើងនិយាយពីវិធីយោធា សំខាន់គេរៀបចំ គេចាប់បានគ្រាន់យើងកម្លាំងវាតិចដូច ថាវាលង់ខ្លួន ។

ដានី ៖ ចូលសឹងរបស់គេ?

សុផល ៖ ចូលសឹងរបស់គេ ។ គេរៀបមុន ។

ដានី ៖ តែអានឹងមិនមែនកងទ័ពរបស់អ៊ំទេ កងទ័ពរបស់ខាងសមុទ្រ តាមុត១៦៤ ។

សុផល ៖ បាទ! មុត ។

ដានី ៖ ស្គាល់គ្នាដែរអ៊ំ ស្គាល់ជាមួយគាត់ដែរ?

សុផល ៖ ស្គាល់ ។

ដានី ៖ ស្គាល់ពេលដែលយើងធ្វើ នេះយើងសហការគ្នាដែរ ក៏ម៉េចកង់ទ័ព?

សុផល ៖ អឺ! បើនិយាយពីរឿងទ័ពនឹង យើងសហការគ្នារហូតនឹង ធម្មតាក្មួយឯងនៅភូមិមួយផ្ទះមួយក៏យើងសហការគ្នាទំនាក់ទំនងគ្នា ដូចតែគ្នា ច្បាប់វាមិនខុសពីរឿងយើងនៅក្នុងសង្គមគ្រួសារមួយទៅគ្រួសារមួយទេ អានឹងច្បាប់វាចឹង ។

ដានី ៖ ប៉ុន្តែពូយើងវាដូចរៀងស្រដៀងៗគ្នា យើងការពារកោះ ហើយខាងនោះកោះថ្មី កោះតាង?

សុផល ៖ អានឹងចេះ ខ្ញុំគ្រាន់ឲ្យក្មួយយល់ចេះ អានឹងវាយុត្តិសាស្ត្រ ឬវិធី ពាក្យកោះត្រល់យើងមើលទទឹងចឹង ។ កោះត្រល់វារៀងម៉េច វានៅកណ្ដាលគេមើលពីខាងនោះ បើយើងមើលពីជ្រុងនេះទៅអានេះវាសរុះសម្រួលជាមួយគ្នា ហើយបរិវេណខាងនេះវាហួសគេហៅសែវានគេ ឯងការពារមើលខាងនេះមក ។ បើមកខាងនេះអានឹងរបស់យើង តួនាទីរបស់យើង ។

ដានី ៖ ដល់ពេលអ៊ំមើលពីកោះខ្យង?

សុផល ៖ ពីជ្រុងមកនេះ ពីកើតមកកើតចឹងមក ។

ដានី ៖ ចឹងកង់ទ័ពរបស់អ៊ំនៅកោះខ្យងដែរ ចាប់ពីម៉ាជំនៀរកោះខ្យង?

សុផល ៖ កោះខ្យង ។

ដានី ៖ អ៊ំខស្សាហ៍ទៅកោះខ្យងដែរ?

សុផល ៖ ខ្ញុំនៅនឹងដែរ នៅដើរចុះដើរឡើង ។

ដានី ៖ ដើរចុះដើរឡើងទៅខាងកោះកុងទៀត?

សុផល ៖ បាទ! ទៅចឹង ។

ដានី ៖ កាលនឹងកង់ទ័ពប្រហែលប៉ុន្មានទៅ ចាប់នៅពីកោះខ្យង រហូតដល់កោះកុង កង់ទ័ពរបស់អ៊ំប៉ុន្មាន?

សុផល ៖ អឺ! អត់ចាំទេក្មួយ ។

ដានី ៖ ម៉ាវរៈសេនាធំ?

សុផល ៖ ម៉ាវរៈសេនាធំជាង ។

ដានី ៖ ជាង ម៉ាវរៈសេនាធំ?

សុផល ៖ ជិតម៉ាកងពលដែរ ។

ដានី ៖ ជិតម៉ាកងពល ។ ហ្នឹងដូចជាកងពលមួយដែរ?

សុផល ៖ បាទ! កងពល រៀបចំកងពលថ្មី ។

ដានី ៖ រៀបចំកន្លែងថ្មី កន្លែងអីគេអានឹង?

ផល ៖ វាគេហៅថាសម្ព័ន្ធមិនទាន់មានជាអីទេ ។

ដានី ៖ មិនទាន់មានអីទេ?

ផល ៖ បាទ! មិនទាន់មានគេហៅថាទ្រង់ទ្រាយវាជាប់ជាមួយខាងលើតែម្ដង ។

ដានី ៖ កាលនឹងមានអុំ មានពីណាខ្លះដែលជាគណៈកន្លែងថ្មី?

ផល ៖ មានមួយនៅធី ឌុំ ។

ដានី ៖ បាទ?

ផល ៖ ធី ឌុំនឹង ។

ដានី ៖ ធី?

ផល ៖ បាទ!

ដានី ៖ ធី គាត់ធ្វើអី?

ផល ៖ អត់ធ្វើអី នៅផ្ទះ ។

ដានី ៖ នៅភូមិណា ភូមិអុំដែរ?

ផល ៖ ភូមិនឹងដែរ ។

ដានី ៖ ភូមិនឹងដែរ ធី ។ ហើយពីណាទៀត?

ផល ៖ ចង់ភ្លេចអស់ហើយ រកនឹកចឹងស្ទួរចឹងចង់ភ្លេចអស់ ។ ខ្ញុំវាមិនសូវចាប់ភ្លឹក មិនសូវចាប់អារម្មណ៍ខ្វាចលើកក្រោយមិនចង់រំលឹកវិញ ចង់និយាយចឹង ។

ដានី ៖ អូ! អត់ចង់រំលឹកឡើងវិញ?

ផល ៖ បាទ! អត់ចង់រំលឹកឡើងវិញ អារឿងកើតឡើង ។

ដានី ៖ ចុះបើអុំអត់រំលឹកឡើងវិញ ក្មួយៗជំនាន់ក្រោយម៉េចដឹង បើអុំធ្លាប់ឆ្លងកាត់?

ផល ៖ វាចង់និយាយថា អតីតកន្លងហួសទៅហើយយើងមិនចង់និយាយ មិនចង់ដើររបាងរៀបរាប់គ្រាន់និយាយថា យើងផ្សះផ្សា ។ ពាក្យថាផ្សះផ្សាចឹង ពាក្យថាផ្សះផ្សាយើងផ្សាឲ្យជាប់យើងមិនបាច់ចាំរំលឹកអីទៀត កាលណាយើងរើរុះអាផ្សះអាផ្សាអីទៀតទៅវាផ្សានឹងទៅជានាំឲ្យមានបញ្ហាទៀត ។

ដានី ៖ អុំគិតថាការផ្សះផ្សា ទាល់តែយើងបំភ្លេចចោល យើងឈប់និយាយទៅអានឹងបានវាផ្សះផ្សា?

ផល ៖ ហ្នឹងហើយយើងឈប់ៗនិយាយឈប់អីពីរឿងអតីតកាលកន្លងៗមិនបាច់និយាយ មិនបាច់អីទេ អានឹងជាគំនិតខ្ញុំចង់និយាយចឹង អត់សូវចាំ អត់សូវចាប់អារម្មណ៍ ពេលដែលចប់

ហើយគឺចប់បណ្តោយ អត់មានឲ្យចង់ដឹង ឲ្យរឿងនិយាយប្រាប់ប្រវត្តិពីក្មេងៗអីចេះចុះខ្ញុំ មិនចង់និយាយទេ ចិត្តគំនិតរបស់ខ្ញុំមិនចង់និយាយ ។

ដានី : អត់ចង់និយាយប្រាប់ក្មេងៗ?

ផល : បាទ! ខ្ជិលកុំឲ្យដឹងរឿង ដឹងពុទ្ធនិយាយក៏មិនដឹងថាទៅជាស្អីដែរ ។

ដានី : ចុះបើអត់និយាយប្រាប់ចឹង ក្មេងៗម៉េចដឹងប្រវត្តិសាស្ត្រស្រុកទេសយើង ។ ថាស្រុកទេសយើងពីមុនមក ឆ្លងកាត់យ៉ាងម៉េច ហើយចាស់ៗពីដើមធ្លាប់តស៊ូអីយ៉ាងម៉េច ហើយដល់ក្រោយមកដើម្បីឲ្យក្មេងៗនឹងដឹង ដើម្បីកសាងប្រទេសទៅក្រោយទៀត ដើម្បីធ្វើម៉េចកន្លែងណាចំនុចល្អ កន្លែងណាចំនុចដែលយើងអត់នេះយើងត្រូវកែធ្វើម៉េច ដើម្បីឲ្យស្រុកយើងទៅស្រួល ។

ផល : វា បើយើងនិយាយពីបញ្ហាទំនាក់ទំនង គេហៅថាការរៀនសូត្រ មានគេអ្នកស្រាវជ្រាវដឹងដែរហើយ ព្រោះឯកសារដែលខ្ញុំរៀនសូត្រ គឺសុទ្ធតែឯកសារចេញមកទាំងអស់ ដូចគ្នាទាំងអស់ដូចគ្នាទាំងអស់ ឯកសារចេញ ។ ប៉ុន្តែពាក្យពេចន៍ គេប្រើខុសគ្នា ដូចសព្វថ្ងៃគេថាអភិវឌ្ឍន៍ ចឹងណា កាលនោះយើងនិយាយថាពាក្យនឹងគ្រាន់តែវា បើយើងនិយាយអន្តរភាព និរន្តរភាព ដេរភាព អានឹងពាក្យនឹងចង់និយាយថាពាក្យវប្បធម៌ប្រើអីផ្សេងៗ ថាគេហៅថាសមតុល្យអីចឹងទៅ ពាក្យនឹងបើនិយាយពីលើកមុនក៏មានប្រើដូចគ្នាដែរ ។ អានឹងអាស្រ័យដល់ពេលយើងស្រុក ខ្ញុំកាលនឹងខ្ញុំទើបនឹងជាប់ ខ្ញុំទៅធ្វើខាងសីលា ផ្នែកសីលាៗពន្យល់ហេតុផលសព្វបែបយ៉ាង ការអភិវឌ្ឍន៍ ផែនការ៥ឆ្នាំ ៣ឆ្នាំវិកិលអីម៉េចៗយើងបាន ។ បាទ! កសាង ។

ដានី : សម័យកសាង?

ផល : សាមគ្គី កសាង ។

ដានី : អានឹងសំខាន់ណាស់ អ៊ីដូចថាសម័យប្រជាជាតិ សម័យកសាង ដល់ពេលសម័យក្រោយ ។

ផល : វាដូចតែគ្នា ន័យដូចគ្នា ប៉ុន្តែវាខុសតិចៗ ។

ដានី : ប៉ុន្តែន័យដូចគ្នា ប៉ុន្តែកាលៈទេសៈដែលយើងប្រើវាខុសគ្នា ពីចន្លោះឆ្នាំណាគេប្រើពាក្យណាដល់ពេលចន្លោះឥឡូវពីឆ្នាំណាមកគេដូរមកប្រើនឹងវិញ ។ ចុះអ៊ំកាលនឹងភូមិភាគនិរតីមានប៉ុន្មានតំបន់ដែរ? អូ!ភូមិភាគបស្ចឹម?

ផល : ភូមិភាគបស្ចឹម?

ដានី : បាទ!

ផល : មានបែងចែក បស្ចឹមនឹងវាមានកោះកុងៗ ។

ដានី ៈ លេខប៉ុន្មាន កោះកុង?

ផល ៈ កោះកុងវាមានខេត្ត តំបន់១១ ។

ដានី ៈ តំបន់១១កោះកុង?

ផល ៈ បាទ! តំបន់១១ ហើយបែងចែកមាន២តំបន់ តំបន់១១នៅខាងកោះកុងនៅម្តុំខាងត្រពាំងរូង អណ្តូងទឹកចេះនៅ នែក!នៅអានឹងតំបន់១១ តំបន់កោះកុង ព្រៃទប់នេះគេហៅតំបន់ប៉ុន្មានខ្ញុំដូច ២៧ប៉ុន្មានភ្លេចហើយ ។

ដានី ៈ ៣០?

ផល ៈ អូ! ៣៧ ២៧ មិនដឹងភ្លេចហើយ ។

ដានី ៈ ពីព្រោះក្នុងតំបន់នឹង ខ្ញុំ៣០ដាងទាំងអស់ ប៉ុន្តែខ្ញុំមិនដឹងជា៣០ ។

ផល ៈ ដោយឡែក១១ ខ្ញុំដឹងថាកោះកុង១១ តំបន់១១ ។ ដូច៧ចុង ២៧ ១៧ ៣៧ មិនដឹងតំបន់៣៧ ។

ដានី ៈ ចុះក្រោមទៀត?

ផល ៈ កំពង់ស្ពឺនឹងតំបន់ ភ្លេច កំពង់ឆ្នាំង៣១ អត់ចាំ ខ្ញុំនឹកឃើញថាវានេះអត់បាន ។ អត់ទេមកចែកតំបន់តាមខេត្ត ។ កាលនឹងយើងមិននិយាយរឿងខេត្តទេ និយាយតំបន់ ។ បើអ្នកតំបន់វិញ គណៈតំបន់ គណៈស្រុក អត់មានអភិបាលស្រុក អភិបាលខេត្តអីចឹងទេ ។

ដានី ៈ ប៉ុន្តែដូចថាជំនាន់អ៊ំមានប្រសាសន៍មិញ ដល់ពេលគណៈតំបន់ចឹងយើងមាន៣នាក់ ។ គណៈតំបន់យើងមានលេខា មានអនុលេខា សមាជិក?

ផល ៈ បាទ! គណៈមាន៣រូប ។

ដានី ៈ ចឹងអ៊ំនៅពេលដែលអ៊ំនៅខាងព្រៃទប់នៅអីនឹង ពេលនឹងយើងការពារសមុទ្រ ឬក៏យើងម៉េច ជួយការពារបង្កបង្កើតផល ឬក៏យ៉ាងម៉េច?

ផល ៈ ន័យសំខាន់បំផុត គេហៅថាបើយើងពេលដែលឈ្នះហើយនឹង យើងបានរៀបចំប្រទេសដែលបានឯករាជ្យហើយ គឺសំខាន់គឺមុខព្រួញសំខាន់គឺបង្កបង្កើនផល ទ័ពទាំងអស់ចូលប្រឡូកជាមួយប្រជាជនធ្វើបង្កបង្កើនផល ។ ប៉ុន្តែន័យទី១យើងនិយាយចេះ ទី១ទ័ពខ្លួនឯងធ្វើដោះស្រាយឲ្យអន្តភាពសម្រាប់ចិញ្ចឹមអន្តភាព ប៉ុន្តែទី២ទៀតនៅជួយដល់សហករណ៍ៗ ។

ដានី ៈ បាទ! ជួយដល់សហករណ៍?

ផល ៈ ជួយស្ទូង ជួយដក ជួយធ្វើការងារអីទាំងអស់ ។

ដានី ៈ ចុះអ៊ំដូចយើងរបបហូបចុកអីយ៉ាងម៉េច កាលនឹងយើងអត់មានទទួលប្រាក់ខែ ដូចពូមានប្រសាសន៍មិញចឹង យើងហូបចុក?

ផល ៈ របបហូបចុក លើគោលការណ៍ចេះ នេះដែលខ្ញុំរៀបចំណែនាំអន្តភាព ហើយអ្នកនាំតាមពីលើ ខ្ញុំថាឥឡូវអន្តភាពឧទាហរណ៍ថា អន្តភាពថាគ្នាប៉ុន្មានថាគ្នា៥០០នាក់ៗ បូកទាំងអស់ខាងក្រោយ មានប្រពន្ធ មានកូន មានចៅអី ប៉ុន្មានថា១០០០នាក់ៗនេះ ម្ចាស់ការខ្លួនឯងរឿងអន្តរ ធ្វើស្រែយ៉ាងម៉េច ដោះស្រាយចិញ្ចឹម១០០០ឲ្យបាន នេះគោលការណ៍កំណត់ចឹង ខ្លួនទីពីងខ្លួន ។ ហើយចឹងរឿងបញ្ហាខាងលើ ផ្តល់ជាគ្រាក់ទ័រឲ្យទៅភ្ជួរៗរាស់ផ្តល់ពូជផ្តល់ធារសម្រាប់ធ្វើ ។ មានបញ្ហាអីធ្វើហើយៗ យើងបើថាធ្វើប៉ុននឹងគ្នាទ័ពម៉ាព្រូលៗគឺ ២-៣ហិចតាហើយៗ ម៉ាព្រូលចុះមនុស្សរាប់រយ ។

ដានី ៈ ប៉ុន្តែយើងមានដាក់ផែនការម៉េច យើងត្រូវបង្កបង្កើនផល យើងត្រូវផ្តល់ផលណាជូនអង្គការថ្នាក់ខាងលើ ហើយយើងម៉េចដែរអានឹង?

ផល ៈ អានេះខាងស្រុក ខាងខេត្ត តំបន់ទេ ។

ដានី ៈ ខាងខេត្ត តំបន់?

ផល ៈ និយាយពីទ័ពគឺម្ចាស់ការខ្លួនឯង ។ និយាយទ័ពអត់មាននិយាយរឿងថាដោះស្រាយស្រូវជូនរដ្ឋអីទេអត់ទេ ដោះស្រាយអន្តភាពឲ្យបាន ។

ដានី ៈ ដោះស្រាយអន្តភាព?

ផល ៈ ដោះស្រាយអន្តភាពឲ្យបាន អត់មានបើកពីរដ្ឋវិញទេ ។

ដានី ៈ ហើយរដ្ឋគេអត់មានផ្តល់ស្បៀង ផ្តល់ម្ហូប?

ផល ៈ ហ៎! លើយើងអ្នកមើលដែរ ចង់និយាយថាបើសិនថាធ្វើបាន ឬមិនបានជាគោលការណ៍ម្ចាស់ការណ៍ បើអាស្រ័យលើគ្នាមិនម្ចាស់ការ ធ្វើជាបះពាល់ខូចខាត រដ្ឋឧបត្ថម្ភឲ្យដែរ មិនមែនជា....។ អានឹងយើងនិយាយតាមគោលការណ៍ តាមច្បាប់ ការណែនាំចឹងហើយ បើសិនអត់យើងត្រូវដោះស្រាយ ផ្គត់ផ្គង់ ។

ដានី ៈ អំកាលនឹងមន្ទីរកងពលនៅលង្វែក ចុះមន្ទីរភូមិភាគនៅណាទៅ?

ផល ៈ កំពង់ស្ពឺ ។

ដានី ៈ នៅកំពង់ស្ពឺ? នៅម្តុំណាកំពង់ស្ពឺ?

ផល ៈ កំពង់ស្ពឺនៅ ។

ដានី ៈ អត់ទេ កំពង់ស្ពឺខ្ញុំស្គាល់ហើយ ប៉ុន្តែវាដូចវាមានច្បារមន មាន?

ផល ៈ នៅច្បារមន ។

ដានី ៈ តាម៉ុកអីគាត់ធ្លាប់ខស្សាហ៍មកដែរ?

ផល ៈ គាត់ ម៉ុក គាត់ដើររែកទាំងអស់ ។

ដានី ៖ គាត់ដើររែកទាំងអស់?

ផល ៖ បាទ! គាត់ដើរទៅនឹង ៨-១០ថ្ងៃ ១ខែ ២ខែទៅមកនេះទៅ ទៅចុះទៅឡើង ។

ដានី ៖ ទៅចុះទៅឡើង?

ផល ៖ បាទ! ដើរចុះ ដើរឡើង ឲ្យគាត់នៅការកសិកម្ម គាត់ខ្លាំង ។

ដានី ៖ គាត់ពូកែកសិកម្ម?

ផល ៖ បាទ! ខ្លាំងណាស់ ។

ដានី ៖ គាត់កសិករ គាត់ធ្លាប់នៅតាកែវ?

ផល ៖ ខ្លាំងនៅកសិករនឹង ។

ដានី ៖ គាត់ស្រុកគាត់នៅតាកែវ គាត់ធ្លាប់ធ្វើស្រែធ្វើអី គាត់ដឹងសុខទុក្ខរបស់ប្រជាជន?

ផល ៖ និយាយរួមធ្វើស្រែធ្វើចំការ រឿងម្យ៉ាង សំខាន់បំផុតគាត់ចុះផ្ទាល់តែម៉ង រូកវ៉ាស់មាត់-កចេះចុះហូរហៃលឆ្កាលដៃឆ្កាលជើងទៅមើលអត់ម៉េចម៉ា យើងចុះផ្ទាល់តែម៉ង ។

ដានី ៖ ...ខស្សាហ៍ជួបគាត់ដែរ?

ផល ៖ ជួបដែរ ។

ដានី ៖ ដូចថាគាត់ណែនាំ គាត់ប្រាប់ថាម៉េចខ្លះ រឿងការងារកសិកម្ម?

ផល ៖ សំខាន់បំផុតកសិករមានដី មានទឹក សំខាន់យើងដោះស្រាយគឺ ធ្វើស្រែ គេហៅថាកុំធ្វើស្រែប្រវាសនឹងមេឃ ។

ដានី ៖ យើងត្រូវមានប្រព័ន្ធ?

ផល ៖ បាទ! ប្រព័ន្ធ ធារាសាស្ត្រ ទឹក ទំនប់ ស្រូវម៉ាឆ្នាំធ្វើឲ្យបាន២ដងទៅ៣ដង ទឹកយើងគិតមើលថា ឥឡូវបើសិនជាធ្វើស្រែ គេហៅថាខែណាក៏ដំណាំប៉ព្រម មិនថាប្រាំងថាវស្សាអានឹងជាគោលការណ៍ ។ ម៉ារដូវ២ដង ៣ដងដាក់ស្រូវ៧ទឹក ស្រូវអ៊ីអ័រ ស្រូវ៣៦នឹង អានឹងគឺគោលការណ៍គឺធ្វើម៉េចឲ្យបានម្ចាស់ការ កុំឲ្យវាប្រជាជន ។

ដានី ៖ ខ្ញុំភ្លេចសួរអ៊ំ កាលនឹងអ៊ំមានគ្រួសារនៅ?

ផល ៖ ខ្ញុំមានហើយ ។

ដានី ៖ អ៊ំរៀបការតាំងពីឆ្នាំណា?

ផល ៖ ៧៥ ។

ដានី ៖ ៧៥ ពេលដែលយើងរំដោះទីក្រុងបាន យើង?

ផល ៖ អឺ!

ដានី ៖ រៀបការជាមួយអ៊ំស្រី?

ជល : អ៊ំមួយទៀត អ៊ំនេះបានក្រោយ៨២ ស្លាប់ហើយនឹង ។

ដានី : ចឹងអ៊ំមានគ្រួសារ២ចឹង?

ជល : ២ហើយ មួយនោះស្លាប់ទៅបានខ្ញុំយកនេះ តាំង៨២វិញ ។

ដានី : គាត់ស្លាប់ដោយសារអីទៅ?

ជល : ៧៩ យួនចូលមកស្លាប់ បែកគ្នា ។

ដានី : គាត់ស្លាប់ បែកគ្នា?

ជល : បាទ! អត់បាយ ។

ដានី : អ៊ំដឹងថាគាត់ស្លាប់?

ជល : បាទ! ស្លាប់ហើយ ។

ដានី : ដល់ពេលយើងនេះនឹង គាត់ស្លាប់ជាមួយអ៊ំដែរ ឬក៏យើងរត់បែកគ្នា?

ជល : អត់ បែកគ្នាខ្ញុំ កាលនឹងពេលយួនចូលមក វៀតណាមចូលមកនឹងណា ខ្ញុំមកនេះ ខ្ញុំឈប់នៅនឹងហើយ ។

ដានី : នៅណាវិញ?

ជល : ខ្ញុំនាំទ័ពមកកំពង់ឆ្នាំងនេះវិញ ។

ដានី : ចុះអ៊ំស្រី គាត់ទៅផ្សេងទៅ?

ជល : គាត់នៅនឹង ។

ដានី : នៅណា?

ជល : នៅមុខលើនៅនឹង ។

ដានី : នៅណានៅនឹង?

ជល : កោះកុង ។

ដានី : កោះកុង?

ជល : បាទ!

ដានី : ចុះកាលនឹងអ៊ំមានកូនចៅទេ?

ជល : ខ្ញុំមានមួយដែរ តែកូននឹងស្លាប់ទាំងម៉ែទាំងកូនអស់ ។

ដានី : ចឹងប្រពន្ធអ៊ំគាត់ឈ្មោះអីទៅ?

ជល : ឈ្មោះ ថេង១ផង ថាផង ។

ដានី : គាត់អ្នកស្រុកណាដែរ?

ជល : បាទ?

ដានី ៖ គាត់អ្នកស្រុកណា?

ផល ៖ កំពង់ឆ្នាំងដូចគ្នាដែរ ។

ដានី ៖ កំពង់ឆ្នាំងនៅស្រុកជាមួយអ៊ំដែរ?

ផល ៖ ស្រុកផ្សេង អឺ! ស្រុកជាមួយតែភូមិផ្សេង ។

ដានី ៖ ហើយចុះកូនអ៊ំ?

ផល ៖ បាទ?

ដានី ៖ កូនៗដែលគាត់?

ផល ៖ កូនស្លាប់ទាំងអស់ ។

ដានី ៖ កូនស្រីប្រុសកាលនោះ?

ផល ៖ កូនស្រី ។

ដានី ៖ កូនស្រីគាត់ឈ្មោះអីទៅ?

ផល ៖ អឺ! អត់ទាន់មាននាម មានឈ្មោះអី ។

ដានី ៖ អូ! នៅតូចនៅឡើយ?

ផល ៖ នៅតូច អត់ទាន់ចេះនិយាយអីស្រួលបួល ។

ដានី ៖ អត់ទាន់ចេះនិយាយ ។ ចុះកាលនឹងអ៊ំដឹងថាគាត់ស្លាប់ ដែលប្រពន្ធអ៊ំ កូនអ៊ំនឹង ស្លាប់ដោយសារយើងរត់ទៅអត់បាយ ឬក៏ស្លាប់ទៅអីទៅ?

ផល ៖ ស្លាប់ បើយើងនិយាយទៅថាតំបន់គ្រុនចាញ់ៗអត់បាយ អត់ទឹកផង ទី១គ្រុនចាញ់ចឹងទៅក៏ឈឺៗចឹងៗ ប៉ះចំណី បានចំណីនឹងគេបានត្រូវបែកហូបៗ ហើយលាប់ត្របែកស្លាប់ទៅ ។

ដានី ៖ ទាំងប្រពន្ធកូននឹង?

ផល ៖ អានឹងប្រពន្ធ ហើយកូនក្រោយមកបានវាស្លាប់ក្រោយ អត់មានអ្នកណាចិញ្ចឹមបីបាច់ថែរក្សាវាសូវអត់បាយអត់ទឹក ។

ដានី ៖ ចុះបងប្អូនខាងប្រពន្ធអីគាត់នៅរស់ដែរអត់?

ផល ៖ ប្អូនមួយនៅនោះ ដល់ពេលចឹង បងផាប់មកផ្ទះវិញមក ។

ដានី ៖ គាត់នៅឃុំណា នៅស្រុក?

ផល ៖ នៅបឹងខ្នារ ។

ដានី ៖ បឹងខ្នារ?

ផល ៖ បាទ!

ដានី : ចុះអ៊ំកាលនឹង ពេលដែលអ៊ំនៅខាងកោះកុង អ៊ំនៅខាងកងទ័ពរហូត ហើយក៏មានផ្លាស់ដែរ?

ផល : ទ័ពៗជួយមើលប្រជាជនដែរ ។

ដានី : ជួយមើលប្រជាជនដែរ?

ផល : បាទ!

ដានី : យើងនាំមកជួយមើលប្រជាជននៅក្នុងតំបន់១១ ក៏តំបន់៣៧?

ផល : តំបន់៣៧ ។

ដានី : កាលនឹងយ៉ាងម៉េច យើងខ្វះកម្មាភិបាល បានឲ្យជួយមើលប្រជាជន?

ផល : កាលនឹងចេះ វាកម្មាភិបាលនឹង មានការចាប់អីរហូត ហើយខ្ញុំរបៀបទៅមកដែរ ដល់ទៅតាមដានហូរហែលខ្ញុំដោយសារតែធ្វើអំពើល្អ ខ្ញុំចេះតែនៅរស់ តែបងប្អូនខ្ញុំស្លាប់អស់ច្រើនណាស់ ហើយរស់តែឯង បងប្អូនបង្កើត បងប្អូនជីដូនមួយស្លាប់ម៉ាជំនាន់នោះច្រើន ។ តែសួរថាមានការឈឺចាប់អត់ទេ ខ្ញុំថាអានឹងជាធម្មតាសេចក្ដីស្លាប់ កុំវីវល់ ។ ចឹងបានខ្ញុំអត់រំលឹករឿងអតីតកាល ។

ដានី : ហ្នឹងដល់ពេលអ៊ំមានប្រសាសន៍ថា មានការដូចថាពេលនឹងមានការចាំមានអីនឹង កាលនឹងដូចតាស៊ីមិនគេដកដែរ?

ផល : កាលចាប់តាស៊ីនឹង ខ្ញុំចង់រឿងគេឆ្លើយដាក់ ថាខ្ញុំទាក់ទិនជាមួយតាស៊ីអីដែរ ដល់ចឹងទៅក៏ចេះតែតាមដាន ខ្ញុំឈរជើងប៉ុន្មាន ឈរជើងយូរដែរនឹង ជិតម៉ាឆ្នាំបានលែងអីវិញ ។

ដានី : អូ! ដល់ពេលគេចាប់តាស៊ីទៅ គេឆ្លើយដាក់អ៊ំៗត្រូវគេដកមកពីកងទ័ពដែរ?

ផល : បាទ!

ដានី : ដល់ហើយវិញ បានគេឲ្យអ៊ំឲ្យទៅជួយមើលប្រជាជននៅតំបន់៣៧?

ផល : អត់ទេ ក្រោយមកវិញបានស្រុករៀបចំ គេចេះឲ្យនៅចេះមើលអត់មានអីធំដុំ ចឹងបានក្រោយមកវៀតណាមចូលបានខ្ញុំ ខាងលើឲ្យខ្ញុំនាំទ័ព១០០០នាក់ បុកមកកំពង់ឆ្នាំងវិញម៉ង ។

ដានី : ចឹងកាលជំនាន់ ដូចថាការដកចាប់តាស៊ីទៅ កាលនោះគណៈតំបន់អី គេដូចគេដកទៅច្រើនដែរ?

ផល : ច្រើន តំបន់ ភូមិភាគច្រើន តែខ្ញុំមិនចាប់អារម្មណ៍ ប៉ុន្តគ្រាន់ថារឿងខ្លួនឯងធ្វើម៉េចការពារ ។

ដានី : ចុះតាសឿងគេដកទៅដែរ?

ផល ៖ អត់ទេ សឿង គាត់មកស្លាប់ក្រោយនេះ ជំនាន់ក្រោយនេះ ។

ដានី ៖ ចុះអ៊ំសាន កាលពេលនោះ គេដកឲ្យគាត់មកគ្រប់គ្រងប្រជាជនវិញដែរ ឬក៏យ៉ាងម៉េច?

ផល ៖ គាត់ប្រជាជន ។

ដានី ៖ បាទ?

ផល ៖ គាត់អត់នៅទ័ព តែគ្រាន់គាត់នៅគ្រប់គ្រងជារួមមីង១ខាងក្រោយគ្រួសារទ័ព អត់មានដូចថាយើងប្រជាជនដែរ ប៉ុនប្រជាជនកងទ័ព ។

ដានី ៖ ប្រជាជនកងទ័ព?

ផល ៖ គ្រួសារកងទ័ព ជួយធ្វើស្រែជួយអីបន្តុបន្ថែមផល មើលទំនប់ មើលប្រឡាយ មើលម៉ាស៊ីនបូមទឹកអីចឹងទៅណា ។

ដានី ៖ គាត់នៅ មកខាងណា?

ផល ៖ លង្វែក ។

ដានី ៖ បាទ?

ផល ៖ លង្វែក ។

ដានី ៖ នៅលង្វែក?

ផល ៖ បាទ! ដល់លង្វែកក្រោយមក ដល់វៀតណាមចូលបានគាត់ទៅកាន់ជួយមើលទ័ពបុកនៅខាងកំពង់ស្ពឺនោះវិញ ។

ដានី ៖ បាទ! ខាងភ្នំស្រួច?

ផល ៖ ខាងភ្នំស្រួច ។

ដានី ៖ ចឹងអ៊ំកាលនឹងដល់ពេលគេចាប់តាស៊ុអីចឹង គេបញ្ជូនជើងអ៊ីចឹង គេដាក់ជំនួសអ្នកថ្មីដែលខាងម៉ាជួរខាង?

ផល ៖ គេមកពិនិត្យផ្ទាល់ គេមកគ្រប់គ្រងផ្ទាល់ អត់ទាន់ដាក់ ។

ដានី ៖ គេមកគ្រប់គ្រងផ្ទាល់ ពីណាគេ?

ផល ៖ ហ៎! មិនដឹងពីណាពីណែទេ ច្របូលច្របល់ហើយខ្ញុំនិយាយមិនត្រូវ ។

ដានី ៖ ចុះពេលនឹងអ៊ំបានជួបតាម៉ុក គាត់បានជួបមក មានជួបគាត់មាននិយាយប្រាប់អ៊ំអីថាម៉េចដែរ?

ផល ៖ គាត់អត់មាននិយាយអីទេ គ្រាន់គាត់ថាមិនឲ្យយើងធ្វើអី ។

ដានី ៖ បាទ?

ផល ៖ គាត់អត់មានថាអីទេ គាត់ថាកុំឲ្យយើងធ្វើអី ។

ដានី ៖ គាត់ថាមិនឲ្យយើងធ្វើអី?

ផល ៖ គាត់ឲ្យនៅម៉ាកន្លែង ។

ដានី ៖ ឲ្យនៅម៉ាកន្លែង អត់ឲ្យយើងធ្វើអី ឲ្យអីនៅម៉ាកន្លែង តំបន់៣៧នឹងទៅ ។ តំបន់៣៧ កន្លែងមន្ទីរតំបន់គេនៅកន្លែងណាទៅ?

ផល ៖ តំបន់ ។

ដានី ៖ មន្ទីរតំបន់៣៧?

ផល ៖ នៅស្រែអំបិល ។

ដានី ៖ ស្រុកស្រែអំបិលម៉ង?

ផល ៖ នៅអាកន្លែងស្រែអំបិលចូលស្រុកស្រែអំបិល ។

ដានី ៖ នៅស្រុកគេរាល់ថ្ងៃនឹង ស្រុកស្រែអំបិល?

ផល ៖ បាទ! វានៅចេះ នៅវាចល័ត ។

ដានី ៖ វាចល័ត?

ផល ៖ ធ្វើផ្ទះនៅម្តុំនឹង អាកន្លែងស្រែអំបិលនឹង វត្តកន្លែងវត្តនឹង ។

ដានី ៖ កន្លែងវត្តៗស្រែអំបិល ។ ចុះតំបន់១១ ខាងកន្លែងមន្ទីរតំបន់១១នៅណាទៅ?

ផល ៖ កន្លងមកតំបន់១១ លើកមុនមិនចាប់ ពេលដែលចាប់អស់រលីងទៅរៀបចំតំបន់នឹងបញ្ចូលគ្នា ។

ដានី ៖ ទៅជាបញ្ចូលតំបន់៣៧វិញ?

ផល ៖ បាទ! តំបន់៣៧ ១១អីនឹង គឺគ្រប់គ្រង អត់មាន ។

ដានី ៖ ពេលគេចាប់ៗឆ្នាំណាដែលគេចាប់?

ផល ៖ អឺ! ដូចភ្លេចឆ្នាំហើយក្មួយ មិនបានចាំវាខ្ញុំមិនសូវចាប់អារម្មណ៍ដែរ ខ្លួនមានបញ្ហាចឹងដែរវាស្មុគស្មាញដែរនឹង ។

ដានី ៖ ចុះអ៊ំយើង ។

ផល ៖ បើគេមិនទុកចិត្តយើង ។

ដានី ៖ គេចាប់នឹងបើតាមអ៊ំដឹង ដូចថាអ៊ំប្រឡូកនៅក្នុងនឹងដែរ គេចាប់នឹងគេចាប់ដោយសារមូលហេតុអីដែរ បើគាត់ធ្វើខុសអីបានគេចាប់?

ផល ៖ វាមិនយល់រឿងជ្រៅ រឿងរាក់ខ្ញុំមិនយល់ គេចោទប្រកាន់រឿងអីៗ ឯងនឹងគេចោទថាទាក់ទិន កាលនឹងវាជំនាន់នឹងខ្វាចចេះ ចង់និយាយថាចូលចោទយើងថាបញ្ហាដែលជាប់ជាមួយកាលនឹងយើងមានពាក្យណា កា.សេ.បេ សេ.អ៊ី.អា ។ សេ.អ៊ី.អា របស់អាមេរិច ។

ដានី ៖ សេ.អ៊ី.អា របស់អាមេរិច?

ផល ៖ បាទ! ដល់ៗ

ដានី ៖ កា.សេ.បេ របស់សូវៀត?

ផល ៖ កា.សេ.បេ របស់សូវៀត យួន សូវៀតៗ

ដានី ៖ យួន ហើយសូវៀត?

ផល ៖ បាទ!

ដានី ៖ ដល់ពេលនឹងដែរ គេចោទអ៊ំថាចូលខ្មែរនឹងដែរ?

ផល ៖ កា.សេ.បេៗ

ដានី ៖ ថា កា.សេ.បេ?

ផល ៖ បាទ!

ដានី ៖ ម៉េចបានគេចោទអ៊ំថាកា.សេ.បេ?

ផល ៖ មិនយល់ ព្រោះតាស៊ីគាត់ពីដើមមិនចូលបក្សវៀតណាមដែរ បក្សពលករវៀតណាម អឺ!បក្សជំនាន់ដែលខ្ញុំនិយាយមិញនឹងណាចូលក្នុងនឹង ជំនាន់យើងចូលបក្ស កាលនឹងបក្សពីឆ្នាំណាៗវាវែងឆ្ងាយណាស់ បើយើងមិនដឹងចាស់ៗយើងអត់ដឹងទេៗ តាំងពីជំនាន់អាចារ្យស្វា, ពោធិ៍កំបោរ, អាចារ្យហែម ជាវ, អ៊ីវ សេស, ក្រឡាហោគង់, ស៊ីវុត្ថា, គឺវាចូលក្នុងអា តាំងពីនឹងមកយើងអត់យល់ទេ យើងក្តាប់មិនបានទេ កាលនឹងចាប់ ទូ សាមុតអីជាប់ៗ យល់ទេរឿងនឹង ឯកសារបានយល់ៗ

ដានី ៖ បាទ! ឯកសារវាមានចឹងដែរ វាមានច្រើនអ៊ំដូចខ្ញុំធ្លាប់អាន?

ផល ៖ ដល់ពេលចឹងរឿងវាច្របូលច្របល់ រឿងចោទប្រកាន់ខាងលើ ខ្ញុំក្តាប់អត់បានទេៗ

ដានី ៖ ប៉ុន្តែដូចថាកាលនឹងអ៊ំចូលបក្ស ចូលអីនឹងតាមខ្មែររបស់តាស៊ីដែរ អីបានគេចោទអ៊ំ?

ផល ៖ អត់ទេ សំខាន់បំផុតថាយើងនៅជាប់ភូមិភាគនឹងៗ ភូមិភាគបស្ចឹម យើងនៅនឹងដែរៗ

ដានី ៖ ប៉ុន្តែគ្រាន់គេតាមដានអ៊ំម៉ារយៈ ហើយបានគេឲ្យអ៊ំមកវិកវឹនការងារធម្មតាវិញ?

ផល ៖ បាទ!

ដានី ៖ គាម៉ុកគាត់ប្រគល់ឲ្យវិញ?

ផល ៖ បាទ! ម៉ារយៈមិនរយៈឆាប់ទេ រយៈយូរៗ

ដានី ៖ រយៈយូរដែរ?

ផល ៖ បាទ! រយៈយូរ នឹកឃើញថាបើសិនណាសម្លាប់ខ្លួនក៏មិនកើត ទៅតាមសមាជីវូៗ គិតថាអំពើល្អ ដូចខ្ញុំថាចឹងៗ

ដានី ៖ បាទៗ យើងធ្វើល្អ?

ផល ៖ ការព្យាយាមធ្វើអំពើល្អទៅ តែប្រៀបធៀបដែលខ្ញុំ កាលពីប្រយុទ្ធគ្នាអីណា ពេលដែលយើងវៃគ្នាអីណា ពួកឈ្លើយសឹកខ្ញុំមិនដែលសម្លាប់អីទេ ពេលចាប់បានអីចឹងនាំគ្នាលើកដៃ ខ្ញុំថាឲ្យកាំភ្លើងៗអស់មកនាំគ្នាទៅផ្ទះណា៎ កុំមកសិរសៀរទៀត ។

ដានី ៖ ឈ្លើយសឹករបស់លន់ នល់?

ផល ៖ បាទ! ជំនាន់លន់ នល់ ខ្ញុំមិនដែលឲ្យទៅ មិនដែលសម្លាប់ មិនដែលធ្វើបាបធ្វើទុកអី អានឹងគ្រាន់ថាយើងមានលក្ខណៈនឹង ដែលថាយើងមានអាយុវែង ។

ដានី ៖ តែអឹងដល់ពេលគេប្រគល់តួនាទីឲ្យអ៊ំវិញ អ៊ំលែងទៅខាងកងទ័ពហើយ?

ផល ៖ នៅទ័ព ។

ដានី ៖ នៅទ័ពវិញ?

ផល ៖ បាទ! មកទ័ពនឹង កាលនោះពេលសភាពការណ៍ចឹងហើយ បានចាប់ផ្ដើមឲ្យខ្ញុំនាំទ័ព១០០០ នាក់មកកំពង់ឆ្នាំង ។

ដានី ៖ អានឹង៧៩ហើយ?

ផល ៖ បាទ! ជាប់នឹងហើយ ។

ដានី ៖ អានឹងពី៧៩?

ផល ៖ យើងយូរហើយ ។

ដានី ៖ ចុះ៧៨ អ៊ំនៅកងទ័ពដដែលដូចថាយើងនៅកងទ័ពផង មើលប្រជាជន?

ផល ៖ បាទ! មើលប្រជាជន ជួយបង្កបង្កើនផល ។

ដានី ៖ បង្កបង្កើនផល?

ផល ៖ បាទ!

ដានី ៖ កាលនឹងយើងបង្កបង្កើនផល ឲ្យប្រជាជនបង្កបង្កើនផល ដើម្បីឲ្យពួកគាត់ហូបចុក ឬបង្កបង្កើនដើម្បីយើងយកស្រូវយកអង្ករជូនដល់អង្គការខាងលើ ពីព្រោះកាន់នឹងយើងត្រូវការស្បៀងអីពីកងទ័ពច្រើនច្បាំង ។

ផល ៖ កាលនឹងវាមានចេះ បែងចែកចំណែក២ ទី១គឺគេកសាងប្រទេសៗដើម្បីយើងយកគ្រាក់ទ័រយកអីមកសម្រាប់ឲ្យប្រជាជនធ្វើកសិកម្ម ។ កាលនឹងគេលើកឡើងថា ផែនការពី១០-១៥ឆ្នាំទៅប្រទេសកសិកម្មសម័យ ទៅឲ្យកសិកម្មជឿនលឿនទៀតនោះ ។ ហើយចឹងពី១០ឆ្នាំទៅ១៥ឆ្នាំ ។ ហើយចឹងការធ្វើរៀបចំទាំងអស់ ទាំងប្រជាជនទាំងទ័ពៗ ៦ទ័ព គឺគេ

ចុះជួយប្រជាជនទៅគ្រប់គ្រងជួយដឹកនាំប្រជាជន ជួយមើលតាមសហករណ៍អានឹងវាចឹង ភារកិច្ចទ័ពគឺចឹងម៉ង ។

ដានី : ភារកិច្ចទ័ពគឺចឹងម៉ង?

ផល : បាទ! ចឹងម៉ង មានត្រាក់ទ័រមានអីនឹង ចូលទៅប្រឡូកបូកប៉ាក់ទៅភ្ជួរទៅរាល់ជាមួយគាត់ ពេលអ្នកណាមានពេលមានសភាពការណ៍អីតែយើងអត់ភ្លេចទេ តួនាទីរបស់ទ័ពការពារ កសាងផងការពារផង អានឹងកាលនឹងគោលការណ៍ចឹង ។

ដានី : កាលនឹងយើងជួយប្រជាជនបង្កបង្កើនផលដើម្បីឲ្យពួកគាត់បានហូបចុក?

ផល : បាទ! ប៉ុន្តែអង្គភាពដែលគេទ័ពនឹង គេម្ចាស់ការខ្លួនគេទេ អត់មានទៅសុំប្រជាជនទេ ឧទាហរណ៍ថាស៊ីសងថាអង្គភាពប្អូនឯង ម៉េចឆ្នាំនឹងបានប៉ុន្មានអីប៉ុន្មាន គ្រប់គ្រាន់ទេ ប៉ុន ប្រើគ្រប់គ្រាន់យើងទុកស្រូវនឹងសម្រាប់ដោះស្រាយឲ្យគ្រួសារយុវជន ។

ដានី : តែអ៊ីកាលនឹង ពេលដែលយើងជួយប្រជាជនបង្កបង្កើនផលនឹង ដូចថាគណៈតំបន់ដែលអ៊ី និយាយដូចថាខាងភូមិភាគគេចាប់អស់?

ផល : ចាប់អស់ ។

ដានី : ចាប់អស់ អត់មានតែងតាំងគណៈតំបន់ថ្មី អត់ទេ?

ផល : កាលនឹងគណៈតំបន់ថ្មី គេរៀបរយជាទ័ពជួយមើល ។

ដានី : អូ! ខ្ញុំយល់ហើយចឹង គេលែងតាំង គេចាត់ឲ្យកងទ័ពនឹងជួយមើល ជួយអីទៅ?

ផល : ហ្នឹងហើយជួយមើលម៉ារយៈក្តី មើលប្រជាជន ។

ដានី : ប៉ុន្តែមើលដល់សភាពការណ៍៧៩?

ផល : អឺ! វាប្រឡូកបូកប៉ាក់ចឹងទៅ ក៏ប្រទូសប្រទ្រាសគ្នាទៅ ។

ដានី : ដល់ពេល៧៩អ៊ីនាំទ័ព១ ០ ០ ០ នាក់មកខាងកំពង់ឆ្នាំង?

ផល : បាទ!

ដានី : តាម៉ុកគាត់ឲ្យនាំមក?

ផល : បាទ!

ដានី : កាលនឹងទ័ពអ៊ីនៅនឹងនាំមកទាំងអស់?

ផល : អត់ទេ រៀបចំកម្លាំងលិចទ័ព មកពីនេះពីនោះ ដាច់មេដាច់កើយប្រមូលបានមករៀបចំ ។

ដានី : មកកំពង់ឆ្នាំង មកម្តុំណាទៅ?

ផល : ខ្ញុំបុកចឹងទៅ ។

ដានី : នៅណា?

ផល ៖ ធ្លាក់ដល់ទន្លេ ។

ដានី ៖ ទន្លេខាងណាវិញ ខេត្តកំពង់ឆ្នាំង?

ផល ៖ ទន្លេខ្ញុំចូលមកដល់ចឹងទម្លាក់ដល់មុខកំពូលចឹងទៅ ។

ដានី ៖ ខាងព្រៃគៀល?

ផល ៖ អឺ! ព្រៃគៀល ខ្ញុំចូលមកជិតម្តុំព្រៃប្រស់ ។

ដានី ៖ ព្រៃប្រស់ មកកំពង់ធំវិញ?

ផល ៖ អឺ! ព្រៃប្រស់ ភ្នំដិល ។

ដានី ៖ ភ្នំដិលនៅណា?

ផល ៖ ភ្នំដិលយើងទៅត្រង់ខេត្តកណ្តាល ទៅចាក់ម៉ាជួរនៅនឹង ។ បាទ! បាធាយនឹង បាទ!ទៅម៉ាជួរ ។

ដានី ៖ ទៅខាងកំពង់ចាមវិញហើយ?

ផល ៖ បាទ! ទៅរ៉ាវៗម៉ាជួរនឹង ។

ដានី ៖ អូ! ចឹងបានន័យថាយើងនាំទ័ព១០០០នឹង ដើម្បីយើងវៃតស៊ូវៃជាមួយកងទ័ពដែលយួនចូលមកនឹង?

ផល ៖ បាទ!

ដានី ៖ តែវៃម៉េចទៅកាលនឹង?

ផល ៖ វៃដើងទឹក ។

ដានី ៖ វៃដើងទឹក?

ផល ៖ អឺ!

ដានី ៖ ទឹកណា ទឹកទន្លេសាប?

ផល ៖ ទន្លេសាប ។ កាលនឹងខ្ញុំទៅនៅជាមួយប្រជាជនទូកខ្ញុំដើរព្រោងព្រាត ប្រជាជនដើរដាក់មោង ចងសន្ទូចនឹងទន្លេពេញ ដឹកនៅម្តុំនឹង ។

ដានី ៖ កាលនឹងនៅជាមួយពីណា ជាមួយពីណាទៀត ដែលយើងដឹកនាំទ័ព តែអ៊ុំម្នាក់ឯងទេហើយក៏?

ផល ៖ ស្លាប់ហើយ ម្នាក់នឹងស្លាប់ហើយ ។

ដានី ៖ ពីណាគេ?

ផល ៖ ប៉ា ជឹម ប៉ា ។

ដានី ៖ បាទ?

ផល ៖ ដឹម ប៉ា ។

ដានី ៖ ដឹម ប៉ា មិនមែនតាប៉ាល់ទេ?

ផល ៖ មិនមែនទេ ដឹម ប៉ា ។

ដានី ៖ គាត់បន្ទាប់អ៊ំ?

ផល ៖ បាទ!

ដានី ៖ ចឹងពេលដើរនឹង យើងយ៉ាងម៉េច យើងអ៊ំនៅចាក់ដើរ ដូចថាកងទ័ពអ៊ំនៅម៉ាជួរនឹង ដល់ពេលណាទៅបានអ៊ំមកតាមព្រំដែនវិញ?

ផល ៖ អឺ!កាលនឹងចេះ បើយើងនិយាយមកវាវែងឆ្ងាយណាស់ កាលទៅនឹងអត់មានដាច់បាយក្រហាយទឹក អត់មានអង្ករហូបទេ ទៅគោះស្រង៉ែហូបទេ ។ ទៅគោះស្រង៉ែ ដាក់ត្រីយកត្រីយកអីទៅយើងហូបត្រីអត់មានបាយហូបទេ ។ ដល់ចឹងបានឆ្នាំ៨២ បានតាម៉ុកហៅខ្ញុំទៅអន្លង់វែងវិញ ។

ដានី ៖ ៨២ហៅអ៊ំទៅអន្លង់វែង?

ផល ៖ បាទ! ហៅទៅអន្លង់វែង ខ្ញុំបានរៀបចំកម្លាំងទ័ពនឹងចុះពីអន្លង់វែងមកធ្វើការតំរួតម្តុំតាមធ្វើការនៅម្តុំ ។ ខ្ញុំដើរធ្វើការខាង គេហៅថាយើងនៅដើម្បីរស់ៗសិន យើងទៅធ្វើការនឹង ចុះមកធ្វើការនៅម្តុំម៉ាជួរ ដែលទៅម៉ាជួរខាងព្រះវិហារ ម្តុំភ្នំត្រេច ប្រាសាទកំពង់ធំព្រះវិហារ សៀមរាប ស្រុកពួក ស្រុកក្រឡាញ់ អានឹងខ្ញុំដើរម៉ាជួរតាមម៉ាជួរនឹងរហូតចុះមកចាក់មក ។

ដានី ៖ ជាមួយកែ ពក ដែរអត់ កែ ពក?

ផល ៖ កែ ពក គាត់នៅខាងកំពង់ធំ គាត់ចុះមកខាងនេះ ហើយខ្ញុំទៅពីនេះមកៗជាមួយអីនែក! សុបិន្ត នៅជាប់ ។

ដានី ៖ ស្រី សុបិន្ត?

ផល ៖ ស្រី សុបិន្តនឹងៗ គាត់នៅខាងទន្លេសាបខាងលើនេះ ខ្ញុំនៅម៉ាជួរជាប់ចឹងទៅ ខ្ញុំចុះមកម៉ាសារៗ ។

ដានី ៖ អ៊ំម៉ាកងពលដែរ?

ផល ៖ បាទ! ខ្ញុំចុះមកចឹងមក ខ្ញុំចុះពីកាលនឹងខ្ញុំធ្វើការរាប់ជាប់តាំងពីនឹងមក ម៉ាជួរស្រុកស្ទោងស្រុកពួក ស្រុកក្រឡាញ់ ស្រុកវ៉ារិន្ទ ។

ដានី ៖ ចុះអ៊ំអ្នកស្រុកកំណើតខាងកំពង់ឆ្នាំង ម៉េចបានអ៊ំអត់ទៅធ្វើការខាងកំពង់ឆ្នាំង មកធ្វើការខាងនឹងវិញ?

ផល ៖ អានឹងការងារ ភារកិច្ច ការងារ ។

ដានី ៖ បើតាមនេះ ភាគច្រើនដូចថាយើងអ្នកស្រុកកំណើតចឹង ដូចថាប្រជាជនស្គាល់អីច្រើន បើយើងចុះទៅធ្វើការតាមស្រុកកំណើតវិញ វាងាយ វាធ្វើឲ្យយើងអាចទំនាក់ទំនងប្រជាជនវាស្រួល ដូចអ៊ំអ្នកនៅចំងាយ?

ផល ៖ គេអ្នកនៅមូលដ្ឋាននឹង អ្នកស្រុកនឹងច្រើនដែរ យើងវាមិនពិបាក អានឹងយើងឃើញការងារនោះវាមានដែរ ។

ដានី ៖ ចឹងដល់ពេលអ៊ំរៀបការក្រោយទៀតឆ្នាំ៨២?

ផល ៖ ឆ្នាំ៨២ ។

ដានី ៖ អ៊ំជួបអ៊ំស្រី?

ផល ៖ ជួបពេលខ្ញុំទៅនឹង ទៅឡើងទៅឆ្នាំ៨២ ទៅលើនឹង ។

ដានី ៖ ទៅអន្លង់វែងនឹង?

ផល ៖ អន្លង់វែងនឹង ។

ដានី ៖ ជួបគាត់នៅអន្លង់វែង?

ផល ៖ នៅអន្លង់វែង ។

ដានី ៖ តាម៉ុកគាត់រៀបការឲ្យ ឬអ៊ំរៀបការខ្លួន?

ផល ៖ ណារៀបការខ្លួនឯងម៉េច?

ដានី ៖ អត់ទេ បានន័យថាអ៊ំត្រូវទៅជាមួយគាត់ទៅដូចថាអ្នកផ្ដើមរៀបការនេះ ចឹងបានហៅចាស់ទុំមករៀបចំជូនអ៊ំ?

ផល ៖ ម៉ុកគាត់មែនរៀបឲ្យទេ ចង់និយាយថាអង្គភាពគេ យើងទទាហរណ៍ថាយើងនៅជាមួយអង្គភាពណា អង្គភាពគេរៀបឲ្យយើងតែម្ដង ។

ដានី ៖ កាលនឹងអ៊ំស្រីនៅអង្គភាពណា?

ផល ៖ អង្គភាពខាងឧត្ដរទិស ។

ដានី ៖ អង្គភាពឧត្ដរទិស បានន័យថាក្រោយ៧៩ហើយ?

ផល ៖ បាទ! នៅជាប់រយៈនឹងរហូតមក ។

ដានី ៖ ចុះកាលជិនាន់៣ឆ្នាំ សម័យកសាងនឹង អ៊ំស្រីអត់នៅជាមួយអ៊ំទេ?

ផល ៖ អត់ទេ ។

ដានី ៖ គាត់នៅកន្លែងផ្សេង?

ផល ៖ គាត់នៅផ្សេង គាត់នៅភ្នំពេញ ។

ដានី ៖ គាត់នៅភ្នំពេញ?

ផល ៖ នៅរោងចក្រ គាត់រោងចក្រខាងថ្មពិល។ តែគ្រួសារគាត់ប្រធានរោងចក្រ ដល់ចឹងគាត់នៅមិនមែនធ្វើជាប្រធានកម្មករអីនៅរោងចក្រនឹងទេ គាត់ជាគ្រួសារមេ។

ដានី ៖ គាត់មានប្តីមុនដែរ?

ផល ៖ អឺ! មានដែរ។

ដានី ៖ ប្តីគាត់មុន គាត់ប្រធានរោងចក្រថ្មពិលនឹង។ ហើយគាត់ហៅថាគ្រួសារកម្មាភិបាល តែគាត់ធ្វើការនៅមើលការងារនឹងដែរ?

ផល ៖ គាត់អត់ធ្វើការងារអីទេ គ្រាន់តែទៅបៀតនឹងគ្រួសារមេនឹង ប៉ុន្តែធ្វើតែប្តី ប្រពន្ធធ្វើអី។

ដានី ៖ ប៉ុនដល់មកដល់អន្លង់វែងនេះ ជួបអ៊ំទៅខាងមន្ទីរគេរៀបចំឲ្យអ៊ំ?

ផល ៖ អត់ទេ អានឹងអង្គភាពនឹង គេលើកឲ្យអង្គភាពគេ យើងនិយាយគេទៅ ឲ្យគេរៀបឲ្យទៅ។

អ្នកជិតខាង ៖ អត់ទោស គ្រួសារគាត់ដែលនៅរោងចក្រនឹង តើបាត់បង់ជីវិត ឬក៏?

ផល ៖ បាត់បង់ជីវិត ស្លាប់ៗដូចគ្នា ខ្ញុំក៏ស្លាប់ គាត់ក៏ស្លាប់ប្តី។ ដល់ចឹងខ្ញុំទៅ ខ្ញុំក៏សួរអឺ!និយាយឲ្យអស់ចឹងចុះ និយាយរឿងយើង។

ដានី ៖ បាទ! និយាយរឿងប្រវត្តិ។

ផល ៖ មុនដំបូងខ្ញុំឡើងទៅ ខ្ញុំសួរសាកសួរនៅស្រុកណាអីណា អ្នកស្រុកណា វានៅស្រុកជាមួយគ្នា។

ដានី ៖ កំពង់ឆ្នាំងដូចគ្នា?

ផល ៖ កំពង់ឆ្នាំងជាមួយគ្នា ដល់ចឹងគាត់នៅភូមិត្រពាំងទេស ខ្ញុំនៅភូមិតាកែវៗ ស្រះអណ្តូងនឹង ដល់ចឹងពេលយើងចឹងទៅលេងផ្ទះទៅលេងតាមផ្លូវជាមួយគ្នាដដែល។ ខ្ញុំក៏សម្រេចចិត្ត ហើយក៏ទៅនៅនឹងក៏នៅជាមួយគេអ្នកខាងខត្តរអត់សូវស្គាល់គេ។ ហើយចឹងខ្ញុំថា អាណិត ហើយយកមកភ្ជាប់ដើម្បីយកមកវិញ មកជិតស្រុកឯង។

ដានី ៖ ចុះកាលនឹងគាត់មានកូននៅ?

ផល ៖ មានមួយកូនបងគេ។

ដានី ៖ គាត់មានកូនមួយដែរ?

ផល ៖ បាទ!

ដានី ៖ ដល់ពេលអ៊ំរៀបការគាត់ហើយ ពេលដែលអ៊ំចុះមកធ្វើការម៉ាជំនៀរនឹង អ៊ំយកមកជាមួយដែរ?

ផល ៖ អត់ទេ! នៅនេះទេ។

ដានី ៖ ចឹងអ៊ំធ្វើការហើយចុះទៅជួបគាត់?

ផល ៖ ជួនកាលមានម៉ាឆ្នាំបានខ្ញុំឡើងទៅវិញ ។

ដានី ៖ អូ! យូរដែរ?

ផល ៖ បាទ! ម៉ាឆ្នាំ ៦ខែ ស្រេចលើខាងលើហោ ។

ដានី ៖ មកយូរៗចឹង គាត់នឹកអ៊ំៗនឹកគាត់ឆាប់ហើយចឹង?

ផល ៖ ធម្មតាទេ អានឹងចឹង ។

ដានី ៖ យើងនៅយូរៗ បើថាកន្លះខែម៉ាខែ យើងទៅមួងអាចវានេះ ។ ចឹងអ៊ំនៅជំនៀវខាងកំពង់ធំខាងព្រះវិហារដល់ពេលណាទៅបានចេញ?

ផល ៖ ខ្ញុំមកនៅឆ្នាំជិតនេះចប់ហើយបានខ្ញុំខាងលើឲ្យឆ្លងមកកំពង់ឆ្នាំងវិញ ។

ដានី ៖ ឆ្លងមកកំពង់ឆ្នាំងវិញ?

ផល ៖ បាទ!

ដានី ៖ ឆ្នាំណា បានមកកំពង់ឆ្នាំង?

ផល ៖ ៨៥ ៨៦ ។

ដានី ៖ ៨៥?

ផល ៖ ៨៥ ៨៦ហ្នឹងហើយ ខ្ញុំហែលកាត់ទន្លេសាបមកតើ ។ កម្លាំងនាំទ័ពហែលកាត់ទន្លេសាបនឹងម៉ង ។

ដានី ៖ អត់មានទូកមានអីឆ្លងទេ?

ផល ៖ ហេ៎! ទូកមានតែទូកដាក់ម៉េចអស់ ទ័ព នាំទ័ពមក ហែលកាត់ ។

ដានី ៖ ចុះដូចអ៊ំៗមេបញ្ជាការចឹង អ៊ំអត់ជិះទូក អ៊ំហែលទឹកដែរ?

ផល ៖ ជិះ ។

ដានី ៖ បាទ?

ផល ៖ ជិះ ។

ដានី ៖ ជិះទូក?

ផល ៖ ចេះ ដែលជិះទូកហែលខ្លះអីខ្លះ ចង់និយាយថា ទូកវាដាក់ថាទូកត្រូវជិះ៦នាក់ ដល់៧វាទាបខ្លាំង ដល់ចឹងយើងឲ្យចុះហែលខ្លះទៅ ។

ដានី ៖ ហែលទៅជិះផង ហែលផង?

ផល ៖ ហែលផងគោងមានបញ្ហាតាមទូកនឹងទៅ ចឹងបានថា ។ ហែលឆ្អែតហើយ ខ្ញុំហែលទឹករាប់គីឡូ ។

ដានី ៖ ហែលទឹកសមុទ្រ ក៏ហែលទឹកទន្លេ?

ផល ៖ ហែលទឹកទន្លេនឹង ទន្លេសាប កាលនឹងខ្ញុំនៅស្មោងៗម្តុំដូនល្អដែលស្គាល់ទេៗ កាលនឹងយើងកំណត់នៅខែ៧ទឹកឡើងៗ ហើយទូកអីយើងលាក់នៅម៉ាដួរនឹងហើយ ដល់ពេលមកទឹកពេញរនាមអស់រលីង ដល់ចឹងគិតធ្វើម៉េចបានទៅដល់ទូក នាំគ្នាហែលៗទឹកជាប់ប្រហែលជា៣គីឡូ កាត់ព្រៃនេះផង អាយើងនេះអាស្រងែ ហើយស្មៅជីបួងស្មៅអីរុំជើងពាក់ព័ន្ធដើរមកអឺ! វេទនា មហាវេទនា ។

ដានី ៖ ហែលទឹកនេះ?

ផល ៖ ហែលទឹកទន្លេ ហែលពាគីឡូម៉ង ហែលទ័ព បើសិនជាម្ចាស់ការ បើសិនណាប៉ះទូកអានឹងយើងថា ទូកយួនចឹងណ៎ បើសិនជាទូកវៀតណាមកយើងគិតម៉េចៗ ថាឥឡូវម៉េចបាច់តម៉េចរត់ទៅណាទេ ទូកមកវ៉ៃយកទូកៗជិះ ។

ដានី ៖ អ៊ំថាចឹង?

ផល ៖ បាទ! វ៉ៃយកទូកជិះបានៗ បុណ្យឲ្យតែមកទេៗ អាងវ៉ៃយកទូកជិះ ។

ដានី ៖ តែមកអត់?

ផល ៖ អត់ៗដែលបាន ។

ដានី ៖ ចឹងអ៊ំមកឆ្លងហែលទឹកទន្លេសាបខាងណា មកខាងកំពង់ឆ្នាំងវិញ?

ផល ៖ បាទ!

ដានី ៖ មកខាងកំពង់ឆ្នាំង មកនៅកន្លែងណា?

ផល ៖ កំពង់ឆ្នាំង ខ្ញុំមកនៅម៉ាដួរភ្នំនេះ ភ្នំអាលាបគុយ ។

ដានី ៖ ភ្នំលាបគុយ ខ្ញុំអត់ស្គាល់?

ផល ៖ អត់ស្គាល់ ។

ដានី ៖ ម្តុំណាទៅ?

ផល ៖ ម្តុំក្រាំងស្គៀរ ។

ដានី ៖ នៅក្រាំងស្គៀរហេ៎?

ផល ៖ បាទ! មកក្រាំងស្គៀរ មកខាងនេះក្រាំងស្គៀរនឹង ភ្នំសោម លាបគុយ ខាងស្រុកបរិបូរ ។

ដានី ៖ ខាងស្រុកបរិបូរ?

ផល ៖ ដល់ឆ្លងៗខ្ញុំឆ្លងជិតពន្លៃនឹង ដល់នេះទាហានតាមវ៉ៃៗ មកប៉ះគ្នាដាក់គ្នានៅនឹង ៣ថ្ងៃ អត់បាន៣ថ្ងៃទេ មើលប្រហែលជាឆ្លងមកម៉ាយប់ ប៉ះមកគេនាំមកប៉ុន្មាន ប្រហែលជា៧០០

នាក់ៗ ហើយខ្ញុំមានកម្លាំងឆ្លងមកវាយបេ៉ករប៉ាក់ផង អត់នេះអត់នោះ កម្លាំងប្រហែលជា ១០០នាក់ទេ ។

ដានី ៖ កងពលអ៊ឹ មានមកជាប់១០០នាក់?

ផល ៖ បាទ! យកមក១០០នាក់ៗគ្នា១០០នាក់ ខ្ញុំហែលយកមក ដល់ចឹងជាប់កម្លាំងនៅនោះដែរ តែខ្ញុំមក កម្លាំងតាមខ្ញុំប្រហែល១០០នាក់ទេ ។ ១០០នាក់ដាក់គ្នាពេលនឹងម៉ង ដាក់ពេលនឹងអត់ទេ វ៉ៃត្រូវមេខាងក្នុងនឹង ។

ដានី ៖ ពីណាគេនឹង មេឈ្មោះអី?

ផល ៖ អឺ! មេបញ្ជាការនឹងត្រូវទៅៗ បាក់ទ័ពទៅវិញទៅ ។

ដានី ៖ គាត់ឈ្មោះអី?

ផល ៖ អត់ស្គាល់ ។

ដានី ៖ អត់ស្គាល់ ។ កាលនឹងអ៊ំនៅជិតនៀវខាងនៅក្រាំងស្មៀរភ្នំនោកន្ទែងគុយនឹង?

ផល ៖ បាទ! កន្ទែងគុយ ។

ដានី ៖ នឹងរយៈពេលប៉ុន្មានទៅ ពី៨៥មក?

ផល ៖ រហូត តាំងពីនឹងរហូតដល់យើងសមាហរណកម្មៗខ្ញុំទៅនេះ ។

ដានី ៖ ចុះកាលនឹងកែវ ពង់នៅខាងណា?

ផល ៖ នៅកំពង់ស្ពឺ ។

ដានី ៖ អ៊ំសាននេះ គាត់នៅកំពង់ស្ពឺដែរ?

ផល ៖ កំពង់ស្ពឺដែរ ។

ដានី ៖ មកកាន់ម៉ាកងពលៗម្នាក់?

ផល ៖ បាទ!

ដានី ៖ ចុះកំពង់ឆ្នាំងអ៊ំមានប៉ុន្មានទៅ មានតែអ៊ំ ឬក៏មានអ្នកផ្សេងទៀត?

ផល ៖ កំពង់ឆ្នាំងមានរៀបចំមកចូលជាមួយកងៗធី ឌុ ។

ដានី ៖ ធី?

ផល ៖ ខ្ញុំថាមិញនឹង ធី គាត់នៅប្រចាំនៅនឹង ដល់ចឹងខ្ញុំមកសហការជាមួយគាត់ទៅរៀបរយម៉េចៗចាត់តាំង ។ ខ្ញុំនៅជា ។

ដានី ៖ កាលនឹងយើងដើរក្នុងព្រៃ ក្នុងភ្នំរហូត ឬក៏មានមកក្នុងស្រុកអីនៅជាមួយប្រជាជនអីដែរ?

ផល ៖ ភូមិ ។

ដានី ៖ នៅភូមិហ៎?

ផល :	នៅភូមិខ្វះ ព្រៃខ្វះ ។

ដានី :	អូ! នៅភូមិខ្វះ នៅព្រៃខ្វះ?

ផល :	យើងមិនចង់នៅភូមិទេ នៅភូមិក៏នៅបានដែរ នៅបញ្ហាបះពាល់ដល់ប្រជាជន មានការរៃគប់គ្នា យើង ។

ដានី :	បាទៗ ពេលដែលយើងនៅភូមិចឹង ពេលណារៃគ្នាទៅ ទាហានអីដកចេញអស់ទៅខាងក្នុងចូលមក វាមានបញ្ហា ។

ផល :	ឬក៏យើងរៃទៅ មានការប៉ះពាល់ប្រជាជនគោក្របីអី តែយើងមិនឲ្យមានបញ្ហា ។

ដានី :	ប៉ុនកាលនឹងគ្រួសារអីអីអត់ទៅជាមួយទេ ទៅតែអ៊ំ?

ផល :	អត់ យកប្រពន្ធ-កូនទៅជាមួយនោះ អត់ទាំងអស់គ្នានឹង ។

ដានី :	ដល់ដែនការយើងធ្វើការនៅតាមចឹងនៅរយៈពេលប៉ុន្មាន ត្រូវមកជួបប្រពន្ធកូននៅខាង?

ផល :	អានឹងស៊ីសងយើងមានការ ។

ដានី :	ស៊ីសងយើងមានការ?

ផល :	បាទ! មានការ ខាងលើហៅ ឬយើងអស់លុយអស់កាក់ ។ យើងដើរទៅថាអស់លុយហើយឲ្យឡើងមកយកវិញ ។

ដានី :	អ៊ំនៅកំពង់ឆ្នាំងរហូតដល់សមាហរណកម្មឆ្នាំ៩០ប៉ុន្មាន?

ផល :	៩៦ ។

ដានី :	៩៦ នៅនឹងរហូតដល់ឆ្នាំ៩៦?

ផល :	បាទ!

ដានី :	សមាហរណកម្មកាលជំនាន់កាលនឹង?

ផល :	៩៦ ៩៥ កាលយើងសមាហរណកម្ម២ដង ខ្ញុំទៅអស់ឡានអស់អី កាលនឹងគេផ្ទុះក្រោយទៀតក៏ខ្ញុំនៅក្នុង ។

ដានី :	នៅក្នុង?

ផល :	បាទ! នៅក្នុងនោះ ។

ដានី :	នៅកន្លែងណា នៅជាមួយ?

ផល :	ខ្ញុំនៅពោធិ៍សាត់ ។

ដានី :	ចូលពោធិ៍សាត់ហើយ?

ផល :	បាទ! ខ្ញុំចូលពោធិ៍សាត់ ។

ដានី :	កាលនឹងសមាហរណកម្មហើយ អ៊ំមានតួនាទីអី?

ផល ៖ អត់មានអីទេ ខ្ញុំ ។

ដានី ៖ អត់ទាន់មានអីទេ ម៉េចចឹង?

ផល ៖ អត់ ដូចខ្ញុំល ។

ដានី ៖ ដូចកែវ ពង់ គាត់សមាហរណកម្មហើយគាត់មានតួនាទីអីនៅកងទ័ព?

ផល ៖ កាលនឹងនៅក្នុងនេះ ឲ្យខ្ញុំនេះ ឲ្យខ្ញុំនៅក្នុងធ្វើប្រធានគុយសេ ខ្ញុំមិនធ្វើ?

ដានី ៖ ធ្វើប្រធានអីគេ?

ផល ៖ ប្រធានគុយសេ ប្រធានមន្ទីរៗកងពលនឹង ។ ហើយយើងភារកិច្ចយើងថ្នាក់នេះ ខ្ញុំខ្ជិល ។

ដានី ៖ ឲ្យអ៊ំមកធ្វើត្រឹមប្រធានកងពល?

ផល ៖ ហ្នឹងហើយ ។

ដានី ៖ ប្រធានមន្ទីរកងពលនៅណា?

ផល ៖ កងពលនេះ គេហៅកងពល១៨ ឥឡូវបញ្ចូលគ្នាជាមួយពួកវរៈ អឺ!វរៈពួកបះបោរនេះ ។

ដានី ៖ កាលនឹងដោយសារ អាពេលអ៊ំចរចាពេលដែលសមាហរណកម្ម អ៊ំមកជាមួយតាម៉ុកវិញ ហើយក៏អត់ទេ ហើយអ៊ំចូលទៀត?

ផល ៖ អត់ទេ ។

ដានី ៖ អត់ទេ?

ផល ៖ បាទ!

ដានី ៖ អ៊ំបែកពីតាម៉ុកហើយ អាពេល?

ផល ៖ បែកហើយ ។

ដានី ៖ ម៉េចបានអ៊ំបែកពីគាត់ ដូចថាគាត់បានក្រុមរបស់គាត់អត់ព្រម?

ផល ៖ អត់ទេ អានឹងភារកិច្ច ការងារភារកិច្ចយើង ពីលើឲ្យមកនឹង ។

ដានី ៖ គេឲ្យមក ៗ ពីព្រោះកន្លែងនឹងវាដូចជាស្មុគស្មាញតិច ខ្ញុំអត់ទាន់សួរយល់ច្បាស់ អាកន្លែងពេលដែលសមាហរណកម្ម ដូចថាក្រុមខ្លះទៅពេលសមាហរណកម្មទៅមានតួនាទីទៅ អ្នកខ្លះដូចថាយើងឋានៈពេលដែលមុនសមាហរណកម្មប្រហែលៗគ្នាដែរ ។ តួនាទីដូចជាកងពលអីដូចតែគ្នានឹង ដល់ពេលសមាហរណកម្មទៅ អ្នកខ្លះគាត់មានតួនាទីអីក្នុងរាជរដ្ឋាភិបាល មានតំណែងអីខ្ពង់ខ្ពស់អីចឹង ។ ម៉ាចំនួនទៀតដូចអស់សួរ?

ផល ៖ អត់ៗ ។

ដានី ៖ អានឹងម៉េចដែរ?

ផល ៖ ខ្ញុំអត់យល់ ។

ដានី ៖ អត់យល់ដែរ?

ផល ៖ បាទ! អត់យល់ កាលនឹងយើងដូចថាឡានតួនាទីម៉េចឲ្យនៅប៉ុននឹងមិនចឹង កន្លែងណានៅកន្លែងនឹង កាលនឹងរដ្ឋាភិបាលប្រកាសចឹង។ ហើយតួនាទីតំណែងនៅដដែល យើងនៅកន្លែងណានៅកន្លែងនឹង នៅសេដ្ឋកិច្ចនយោបាយគ្មានទេ។ ចង់និយាយថាយើង ក្រោយមកគាត់ថាការរៀបរយតិចៗ ខ្ញុំកាលនឹងមូលហេតុចេះ កាលនឹងខ្ញុំមកក្រោយគេ កាលនឹងគេមករៀបចំអីចប់ហើយ។ គេមករៀបចំអង្គភាពម៉េចៗខ្ញុំនៅនេះឡើយ នៅរមាសកំពង់ឆ្នាំងនោះ។ កម្លាំងខ្ញុំនៅនឹងក្រោយគេៗមក ដល់គេរៀបចំអស់ហើយ រៀបចំអស់គេចាប់តាំងឲ្យខ្ញុំបញ្ចូលជាមួយគេ។ ខ្ញុំថាឈប់បណ្ដោយ។ ហើយខ្ញុំទៅកន្លែងជួបនឹង ជួបមាសសុភា, កែ គឹមយ៉ាន, ប៉ុល សារឿន, ទៅជួបនៅភ្នំពេញនឹង។ ជួបនឹងគាត់ហៅទៅជួបនៅនឹង ហើយខ្ញុំទៅជួបនៅនឹង ហើយវ៉ា គេនាំដើរលេងដើរអី។

ដានី ៖ ពីណានាំដើរលេង?

ផល ៖ វ៉ា។

ដានី ៖ ជា ដាវ៉ា?

ផល ៖ មិនមែនជា ដាវ៉ាទេ វ៉ានឹងគេបន្ទាប់តែឥឡូវផ្កាយ២ហើយ នាំដើរលេងចឹងទៅខ្ញុំទៅលេងជាស្រីជាមួយអីខ្ញុំអត់លេងចូល នាំ។ ដល់ចឹងបានខ្ញុំទៅចាំយកកាប៉ាល់ហោះ កង់ខ្ញុំនឹងចាំឲ្យជិះកាប៉ាល់ហោះ អាកន្ទុំរុយមកនេះវិញ។ ដល់ចឹងខ្ញុំនឹកឃើញថាកាប៉ាល់ហោះ ចាំមើលម៉ាថ្ងៃ២ថ្ងៃក៏មិនឃើញ ២-៤-៥ថ្ងៃម៉ាអាទិត្យអត់ឃើញនៅតែនឹង កង់ទ័ពដើរតាវ៉េតាវ៉េខ្វះ ដឹកស្រវឹង។ ខ្ញុំគិតម៉េចទេ ចឹងនាំគ្នាតស់ចាប់រទេះភ្លើងជិះ ចាប់រទេះភ្លើងពីរមាសនឹងជិះមកចុះពោធិ៍សាត់។

ដានី ៖ ចុះព្រំដែន?

ផល ៖ បាទ! ជិះ។

ដានី ៖ ឆ្នាំណាអានឹង?

ផល ៖ អានឹងយើងរៀបចំ គេរៀបចំអង្គភាពអីនេះហូរហែលអស់ហើយ ខ្ញុំមកនឹងមកឡើងជិះរទេះភ្លើងមកៗចុះនៅរមាស អឺ!ចុះនៅពោធិ៍សាត់ បានចុះមកចូលនៅកន្លែងយើងក្រវ៉ាញនេះ សម្រាកនៅនឹង គេសាកសួរម៉េចៗ គេរៀបចំៗអស់ហើយកង់ទ័ព។ ដល់ចឹងខ្ញុំអត់មានអីគេបញ្ចូលចឹង។ ដល់បញ្ចូលចឹងខ្ញុំអត់ ខ្ជិលណាស់។

ដានី ៖ គេបញ្ចូលឲ្យអ៊ំមកធ្វើនៅមន្ទីរកងពលអីចឹង?

ផល ៖ បាទ!

ដានី ៖ ដល់ចឹងអ៊ំឈប់ទៅ?

ផល ៖ ឈប់ ។

ដានី ៖ ដល់ពេលអ៊ំចាប់មកធ្វើមន្ទីរអភិរក្សខាងបរិស្ថាន យ៉ាងម៉េចអានឹងៗរបស់ក្នុងក្របខ័ណ្ឌរបស់រាជរដ្ឋាភិបាលដែរ?

ផល ៖ របស់រដ្ឋាភិបាល ក្រសួងបរិស្ថាន ។

ដានី ៖ អានឹងយ៉ាងម៉េចបានអ៊ំចូល?

ផល ៖ ចេះ កាលដឹបូងឲ្យខ្ញុំមកធ្វើអភិបាលរង ខ្ញុំអត់ធ្វើ ។

ដានី ៖ អភិបាលរងវាលវែង?

ផល ៖ ស្រុកហ្នឹង បាទ! ។

ដានី ៖ ម៉េចបានអ៊ំអត់ធ្វើ?

ផល ៖ ខ្ញុំអត់ធ្វើគិតថា រងគេខ្ជិលធ្វើ សុខថាអីក៏ដោយ តូចធំក៏ដោយឲ្យបានមេគេ ។ ហើយចឹងខ្ញុំធ្វើប្រធានមន្ទីរបរិស្ថាន ប្រធានអភិរក្ស ខ្ញុំធ្វើប្រធាន ។

ដានី ៖ កាលនឹងជំនាន់ណា អ៊ំអ្នូង យ៉ន់?

ផល ៖ អ៊ំយ៉ន់ អភិបាល ។

ដានី ៖ ដល់ពេលនឹងគេឲ្យអ៊ំមកអភិបាលរងជាមួយគាត់ដែរ?

ផល ៖ បាទ! ឲ្យខ្ញុំធ្វើអភិបាលរងៗខ្ញុំមិនធ្វើឲ្យធ្វើមេឃុំៗខ្ញុំអត់ធ្វើ ។

ដានី ៖ ដល់ពេលអ៊ំទៅធ្វើប្រធាន?

ផល ៖ ចង់ធ្វើប្រធាននោះ ។

ដានី ៖ ចង់ធ្វើប្រធានមន្ទីរអភិរក្ស?

ផល ៖ ប្រធានស្នាក់ការ ។

ដានី ៖ ប្រធានស្នាក់ការអភិរក្ស?

ផល ៖ បាទ!

ដានី ៖ អានឹងក្រោមរបស់ក្រសួងវិញ?

ផល ៖ បាទ! ក្រសួង ។

ដានី ៖ ក្រសួងបរិស្ថាន?

ផល ៖ បាទ!

ដានី ៖ អត់នៅក្រោមស្រុកទេ?

ផល ៖ អត់ទេ ។

ដានី ៖ អ៊ំធ្វើនៅនឹងរហូតដល់ឆ្នាំ២០០៩ម៉ង?

ផល ៖ ឆ្នាំ២០០០ រហូតមកដល់ទើបនឹងឈប់២ឆ្នាំ ។

ដានី ៖ ចឹងចាប់ពីឆ្នាំ២០០០មកបានអ៊ំធ្វើ?

ផល ៖ បាទ!

ដានី ៖ ចឹងពីឆ្នាំ៩៥ ៩៦រហូតដល់ឆ្នាំ២០០០ អ៊ំអត់ធ្វើអី?

ផល ៖ អត់ធ្វើអី ។

ដានី ៖ អ៊ំនៅតែផ្ទះ?

ផល ៖ បាទ! នៅផ្ទះ ។

ដានី ៖ ប៉ុន្តែនៅក្របខ័ណ្ឌកងទ័ពដែរ អត់ទេ?

ផល ៖ ទ័ពដែរ តែទ័ពខ្ញុំដាក់យុទ្ធជន ខ្ញុំដាក់អត់មានធ្វើអី ដាក់យុទ្ធជន ។ ចុះវាអស់ហើយខ្ញុំដាក់យុទ្ធជនម៉ង យកធ្វើអីៗដាក់យុទ្ធជន ។

ដានី ៖ ប៉ុន្តែកាលនឹងខាងលើខាងអីគេខស្បាហ៍ទាក់ទងមកឲ្យអ៊ំធ្វើការងារដែរ?

ផល ៖ គេអត់សូវស្គាល់យើងដែរ មិនសូវស្គាល់ ។

ដានី ៖ បាទ?

ផល ៖ គេអត់សូវស្គាល់ ។

ដានី ៖ គេអត់សូវស្គាល់?

ផល ៖ បាទ! គេមិនសូវរំលឹកស្រាវជ្រាវ ព្រោះរៀបចំរចនាសម្ព័ន្ធរួចអស់ហើយ ។

ដានី ៖ ប៉ុន្តែគេឲ្យអ៊ំធ្វើអភិបាលរងគេម៉េច អ៊ំទៅទាក់ទងគេ ឬយ៉ាងម៉េចបានគេឲ្យអ៊ំធ្វើ?

ផល ៖ អត់ទេ អានឹងគ្នាឯងស្គាល់ហៅទៅ ដឹងថាយើងមេចាស់ចឹងទៅហៅ ។

ដានី ៖ មេចាស់ហៅទៅ?

ផល ៖ បាទ!

ដានី ៖ ខាងយើងដែរ?

ផល ៖ បាទ! ហៅ ។

ដានី ៖ ប៉ុន្តែខាងក្នុងនោះ គេប្រគល់តួនាទីឲ្យខាងយើង?

ផល ៖ ខាងយើងអ្នករៀបរយ ។

ដានី ៖ ខាងយើងអ្នករៀបរយតើ?

ផល ៖ អឺ! ហ្នឹងហើយ ។

ដានី ៖ ចឹង?

ជល : តែខ្ញុំអត់ចង់ ។

ដានី : អត់ចង់?

ជល : បាទ! ខ្ញុំចង់រកស៊ីនឹងណា ឡានទិញឡានដឹកអីវ៉ាន់លក់តិចតួច របស់របរដឹកយកមកលក់រកស៊ី ។

ដានី : ហើយពេលអ៊ំធ្វើប្រធានមន្ទីរអភិរក្ស ប្រធានស្នាក់ការខាងណា ខាងយើងចាត់តែងដែរ?

ជល : បាទ?

ដានី : ដល់ពេលអ៊ំមកធ្វើប្រធានស្នាក់ការអភិរក្សខាងបរិស្ថាន?

ជល : ខ្ញុំធ្វើអានឹង គឺយើងដាក់ពាក្យទៅរដ្ឋាភិបាល ទៅក្រសួង ។

ដានី : ដាក់ទៅក្រសួង?

ជល : បាទ! ក្រសួងគេប្រថាប់ត្រា យើងដាក់ទៅផ្ញើទៅនៅមន្ទីរបរិស្ថានៗបញ្ជូនទៅលើទៀត ។

ដានី : ចឹងប្រធានទីស្នាក់ការឆ្លងទៅ ប្រធានមន្ទីរបរិស្ថាននៅពោធិ៍សាត់?

ជល : បាទ!

ដានី : ហើយបានគេបញ្ជូនទៅលើទៀត?

ជល : បាទ!

ដានី : ឥឡូវអ៊ំ ដល់ពេលឆ្នាំ២០០៩នេះ អ៊ំឈរឈ្មោះខាងក្រុមប្រឹក្សាស្រុកវិញ?

ជល : បាទ!

ដានី : អានឹងយើងឈរឈ្មោះខ្លួនឯងទេ?

ជល : បាទ! អានឹងយើងត្រូវអស់អាណត្តិនេះវាចប់ហើយ យើងនៅធ្វើទៅ ។

ដានី : ខាងក្រុមប្រឹក្សាស្រុកៗម៉ាអាណត្តិប៉ុន្មានឆ្នាំ?

ជល : ៥ ។

ដានី : ៥ឆ្នាំ ។ ប៉ុន្មាននាក់ក្រុមប្រឹក្សាស្រុកវាលវែង?

ជល : ៧រូប ។

ដានី : ៧?

ជល : អឺ!

ដានី : នៅក្នុង៧រូបនឹងមានប្រធានក្រុមប្រឹក្សាម៉ារូប?

ជល : បាទ!

ដានី : ប្រធាន ហើយអនុប្រធានដែរ?

ជល : អត់មានអនុទេ ។

ដានី ៖ អត់មានអនុទេ ហើយនឹងក្រុមប្រឹក្សាទាំងអស់?

ផល ៖ បាទ! មានប្រធាន មានសមាជិកៗទាំងអស់ទាំង៦នឹង តែគ្រាន់ថាមានលំដាប់លេខ១ លេខ២ លេខ៣ គេដាក់តាមលេខៗ

ដានី ៖ អានឹងគេបោះឆ្នោត ហើយអីគេ?

ផល ៖ បាទ! បោះឆ្នោតៗ

ដានី ៖ គេបោះឆ្នោតនៅក្នុងមន្ត្រីរាជការក្នុងឃុំបោះឆ្នោត ឬប្រជាជន?

ផល ៖ បោះឆ្នោតទូទៅៗ

ដានី ៖ បោះឆ្នោតទូទៅ?

ផល ៖ បាទ! បោះឆ្នោតទៅ យើងៗ

ដានី ៖ តែអឺ! អ៊ំទៅធ្វើការរាល់ថ្ងៃដែរ ទៅ?

ផល ៖ បាទ! ទៅៗ

ដានី ៖ អ៊ំទទួលខាងអីឥឡូវខាង....?

ផល ៖ ការងារនឹងវា ដល់យើងនិយាយទៅមក.... យើងចុះទៅតាមឃុំៗ

ដានី ៖ ចុះតាមឃុំ?

ផល ៖ បាទ! ចុះតាមឃុំនេះៗ ៗ

ដានី ៖ នៅឃុំណាៗ?

ផល ៖ បាទ!

ដានី ៖ អ៊ីខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំអ៊ំទៀត ហើយចឹងអ៊ំមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំអ៊ំទេ?

ផល ៖ ខ្ញុំរឿងគ្មានអីបន្ថែមទៀតក្មួយ ចង់និយាយថាខ្ញុំសំណូមពរចេះទេ សំណូមពរថាការដែលក្មួយចង់ដឹងចង់យល់ពីបញ្ហាប្រវត្តិកាលអីពីរឿងខ្ញុំៗ ខ្ញុំឃើញថាខ្ញុំអត់មានលាក់លៀមទេ ខ្ញុំនិយាយហេតុផលទាំងអស់ៗ ហេតុផលដែលនិយាយនេះ គឺសំខាន់ត្រង់ថាយើងមិនទៅយករូបយកអីខ្ញុំៗសំណូមពរប៉ុននឹង មិនបាច់យករូបខ្ញុំ ហើយថតៗ ខ្ញុំមិនចង់ឲ្យថតៗមនុស្សអត់ពាក់ ពាក់អីផងខ្លួនទទេរ ខ្ញុំសុំសំណូមពរគឺឲ្យលុបរូបខ្ញុំចេញ ហើយរឿងបញ្ហាអ្វីដែលនិយាយអឌិតកាលនឹង ឧទាហរណ៍ថាពិចារណាថែមទៀតមក ការនិយាយវែងពេកឥតប្រយោជន៍ យើងកុំយកពាក្យៗជជែកគ្នាលេង ធម្មតាមិញ និយាយហូរហែលនឹង អានឹងជារឿងមួយៗ ប៉ុន្តែយើងនិយាយពីថាជំណាក់កាលនេះ ជំណាក់នោះវាចឹងទេ វាជារឿងមួយថា ដូចខ្ញុំជម្រាបមកថា ខ្ញុំមិនចង់និយាយពីរឿងអឌិតកាល រហូតដល់អាមេរិច និង

អូស្រ្តាលី អឺ!ដែលអង់គ្លេសមកសម្លាស់ខ្ញុំអត់និយាយរកជងនឹង ។ ខ្ញុំអត់ឲ្យជួបទេ ខ្ញុំអត់ជួបចង់ជួប ខ្ញុំថាខ្ជិលខ្ញុំខ្ជិលនិយាយ ។

ដានី : អូ! ចឹងអ៊ំអត់ដែលនិយាយជាមួយគេទេ?

ផល : អត់ដែលនិយាយទេ ទើបតែក្មួយឯងទេ បានខ្ញុំនិយាយនោះ ចឹងបានថាការនិយាយនេះអ៊ីៗផ្សេងៗទាំងអស់ ខ្ញុំមិនឲ្យជាប់រូបខ្ញុំ មិនឲ្យថតរូបខ្ញុំ ហើយកុំឲ្យនិយាយពីរឿងថាផ្សាយពីអីម៉េចពីរូបខ្ញុំម៉េចៗ ។

ដានី : អត់ឲ្យខ្ញុំសរសេរជាអត្ថបទអីទាក់ទងពីប្រវត្តិអ៊ំទេ?

ផល : បាទ! មិនបាច់ទេ ។

ដានី : គ្រាន់ឲ្យដឹងថា ។

ផល : គ្រាន់លើជាៗគេហៅថា អត់បាច់លើជាបុគ្គលាដ្ឋានអីទេ ចង់លើកជាបុគ្គលអីទេ លើកជាប្រវត្តិតស៊ូពី ។

ដានី : កុំលើកចំអ៊ំអីចេះៗអី ជាហូរហែលកុំ ។

ផល : បាទៗ ចំណុចណាគួរចាប់អារម្មណ៍ ដែលក្មួយចង់ដឹងពីអតីតកាលចង់ដឹងជំនាន់ក្រោយចង់ដឹងទេ កុំបាច់យកឈ្មោះខ្ញុំឲ្យលើកជាឲ្យរឿងរ៉ាវ លើកជាឈ្មោះក ឈ្មោះខ អីទៅ ។ អានឹងសំណូមពរចឹងធ្វើបានទេក្មួយ?

ដានី : បាទ! បាន ប៉ុន្តែម៉េចបានអ៊ំខ្លាចសម័យយើងឥឡូវ?

ផល : ខ្ញុំអត់ខ្លាចទេ ចង់និយាយថា ខ្ញុំឈប់រវីរវល់រឿងអីផ្សេង ចង់អត់ឲ្យជំពាក់ជំពិនអី ។

អ្នកជិតខាង : ខ្លាចចេះ គេផ្សព្វផ្សាយមានអ្នកផ្សេងគេមកតាមទៀត ។

ដានី : បាទៗ ។ អានឹងខ្ញុំយល់ ។

ផល : ខ្ញុំមិនចង់ៗនិយាយទោះបីថាអ្នកមុខ អ្នកក្រោយ ខ្ញុំអត់និយាយតទៀតម៉ង ។

ដានី : បាទ! អត់និយាយទៀតទេ?

ផល : អត់និយាយទៀតទេ ។

ដានី : អត់និយាយទៀត បាទ!ខ្ញុំអ្នកស្រាវជ្រាវនេះខ្ញុំយល់ពីអ៊ីដែលអ៊ំមានប្រសាសន៍មិញ ។

វណ្ណៈ : ឧបមាថាសាច់រឿងអាចសរសេរបាន ប៉ុន្តែមិនបាច់ដាក់ឈ្មោះដាក់អីអ៊ំ ។

ផល : បាទ! សំណូមពរ ធ្វើម៉េចក្មួយមិនបាច់ដាក់ឈ្មោះខ្ញុំទេ ។

ដានី : បាទ! ចឹងខ្ញុំអរគុណអ៊ំច្រើន ។

«ចប់»